# សៀវភៅគតិលោក
## ភាគ ទី២



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

ChanBoKeo.com

## ពាលវត្ត

អន្តេវាសិកឆ្លើយតបគ្រូវិញទៀតថា សូមទានព្រះតេជព្រះគុណ វីអំពើពុតពាលដែលវាតែងប្រព្រឹត្តបៀតបៀនអ្នកស្រុកនោះ តើដោយហេតុយ៉ាងណាខ្លះ?។

គ្រូប្រាប់ថា ឯមនុស្សពាលនោះកាលវាបានឱកាសនឹងបៀតបៀនអ្នកស្រុកនោះ ព្រោះហេតុអ្នកស្រុកជាបច្ច័យ គឺថាពាលនោះគយឃ្លាំចាំស្តាប់ហេតុរបស់អ្នកស្រុកបាន ព្រោះអ្នកខ្លះបានជម្ងឺឈឺចាប់ជាក្តីរំខាន ហើយក៏មានចិត្តប្រារព្ធ ចង់បានគ្រូពេទ្យនឹងរក្សារោគ អ្នកខ្លះត្រូវការចង់បានខ្ញុំកំដរនឹងធ្វើស្រែ ធ្វើចំការ អ្នកខ្លះត្រូវការឈើព្រៃនឹងធ្វើផ្ទះ អ្នកខ្លះចង់បានគ្រឿងមាសប្រាក់ជាដើម សេចក្តីត្រូវការរបស់អ្នកស្រុកនោះ ក៏ជាហេតុនឹងកើតឡើងដល់មនុស្សពាលៗ នោះវាដឹងថាភូមិនោះផ្ទះនោះត្រូវការវត្ថុនោះៗទើបវាប្រកបការតាមផ្លូវ ដែលពួកអ្នកស្រុកប្រាថ្នានោះឯង មនុស្សក្នុងលោកនេះកាលបើមានសេចក្តីប្រាថ្នានូវវត្ថុអ្វីៗ អារម្មណ៍នោះប្រារព្ធប្រព្រឹត្តទៅរឿយៗលុះមានអ្នកណាមកនិយាយត្រូវត្រង់វត្ថុដែលខ្លួនប្រាថ្នាប្រារព្ធនេះ ក៏កើតសេចក្តីគាប់ចិត្ត១ វំពេច



ទៅដោយសារអារម្មណ៍នោះចាប់មកហើយរឿយៗ ម្ល៉ោះហើយក៏ភ្លើតភ្លើនទៅ ជាផ្លូវឲ្យមនុស្សពាលបានឱកាសចូលយាយីបានដូចនិទានចៅឡប ធ្វើឲ្យមនុស្សពាលបញ្ឆោតយកប្រាក់១០០បាទទៅបាន។

## រឿងចៅឡបនឹងចៅប្រាក់

ឯរឿងចៅឡកនោះថាកាលនោះមានមនុស្សពាលម្នាក់ឈ្មោះចៅប្រាក់នៅស្រុកបាត់ដំបង ចៅប្រាក់នោះជាខ្ញុំលោកសុភាទេស ថ្លៃខ្លួនវា២០០បាទ លុះនៅយូរមកក៏លោកសុភាទេស ប្រើឲ្យទៅឃ្វាលក្របីនឹងក្មេងម្នាក់ទៀត ឃ្វាលនៅឯវាលស្រែក្រៅចៅប្រាក់នោះលុះឃ្វាលបន្តិចទៅ ក៏និយាយនឹងក្មេងនោះថា យើងនៅឃ្វាលក្របីទាំងពីរនាក់នេះឃើញព្រួយការពេកណាស់ វិស័យក្របី១ក៏ដូចជាក្របី១០ក៏យប់ដូចគ្នា បើដូច្នេះអញគិតទៅឃើញថានៅឃ្វាលទាំងពីរនាក់នេះ ក៏ជាការព្រួយសំបាកណាស់ ព្រោះពុំមានអ្នកណានឹងរកអាហារស្បៀងបញ្ជូនមកឲ្យ បើដូច្នេះចូរឯងនៅឃ្វាលតែម្នាក់ឯងចុះ អញនឹងទៅរកស៊ីឈ្នួលពាត់គេ ក្រែងបានប្រាក់កាស ក៏នឹងទិញស្បៀងមកលៀងចិញ្ចឹមគ្នា ទៅតាមជាតិអ្នកកំសត់កុំឲ្យអត់

ឃ្លានពេកឯក្មេងនោះ លុះបានស្ដាប់ចៅប្រាក់ថាដូច្នោះក៏ព្រម
តាម ទើបទទួលការឃ្វាលក្របីនោះនៅម្នាក់ឯង បើកឲ្យចៅ
ប្រាក់ទៅរកស៊ីឈ្នួលគេឯភូមិស្ទឹង ឯចៅប្រាក់ដើរមករកធ្វើ
ការស៊ីឈ្នួលគេក៏រកធ្វើពុំបាន ដើរទៅៗបានជួបនឹងមនុស្ស
ពាលម្នាក់ ឈ្មោះនាយជាៗ នោះជាតិជាជ្វាចាមបានសូមគ្នាជា
មិត្តភក្តិ នាំគ្នាទៅសំណាក់នឹងផ្ទះនាយអ៊ូជាបងធំនាយជា លុះ
ថ្ងៃ១នាយជានិយាយនឹងចៅប្រាក់ថា យើងនឹងគិតប្រកបការរក
ស៊ីតាមគេអ្នកស្រុកនេះឃើញជាពុំបាន ព្រោះពុំមានដើមទុន
អ្វីសោះ បើដូច្នោះយើងគិតលក់ខ្លួនថ្លៃចែកគ្នា ឯចៅប្រាក់
ឆ្លើយថាត្រូវមែនហើយសំឡាញ់គិត នោះបើដូច្នោះសំឡាញ់
ឯងធ្វើជានាយចៅហ្វាយអញៗធ្វើជាខ្ញុំ ឯងយកអញទៅលក់
ចុះ នាយជាឮចៅប្រាក់ព្រមចិត្តដូច្នោះ ក៏ត្រេកអរពេកណាស់
ទើបនាំគ្នាទៅឯភូមិចុងគុល ដើរស្ដាប់ហេតុអ្នកស្រុក គឺផ្ទះណា
ត្រូវការចង់បានតួខាង លុះស៊ើបហេតុទៅក៏ដឹងថា ផ្ទះចៅឡុក
ត្រូវការរកមនុស្សនឹងច្រូតស្រូវ ទើបចៅប្រាក់និយាយថាមែន
ហើយអ្នកឡុចនោះគាត់ក៏ស្គាល់អញដែរ ព្រោះពីដើមអញ
ធ្លាប់នៅជិតខាងគាត់ ប្រសិនជាយើងទៅរកប្រាក់គាត់ គង់



គាត់លោះយើងមិនខាន ឯនាយជាក៏យល់តាមទើបនាំគ្នាទៅកាន់
ផ្ទះចៅឡុច ដល់ហើយក៏ឡើងទៅសំពះសួរចៅឡុចតាមការ
សមគួរ ឯចៅឡុចក៏សួរថា អើជីប្រាក់ឯងសព្វថ្ងៃនេះទៅនឹង
អ្នកឯណា ចៅប្រាក់ក៏ឆ្លើយថា បាទខ្ញុំសព្វថ្ងៃនេះនៅនឹងអ្នកជា
ដែលមកផងនេះឯង ឥឡូវនេះគាត់ថានឹងទៅស្រុកគាត់ គឺស្រុក
បន្ទាយភ្នំពេញវិញ គាត់នឹងយកខ្ញុំបាទទៅផង ខ្ញុំបាទពុំចង់ទៅ
ព្រោះស្រុកឆ្ងាយ គឺរកប្រាក់ជូនគាត់វិញ គាត់ក៏ព្រមតាមចិត្ត
ហេតុនេះខ្ញុំបាទចូលមករកប្រាក់អ្នក សូមឲ្យអ្នកមេត្តាលោះខ្ញុំ
បាទផងឯចៅឡុចបានស្ដាប់ពាក្យចៅប្រាក់ដូច្នោះ ក៏សួរទៅ
នាយជាថាអើអ្នកឯងជានាយជីប្រាក់ លោះគ្នាមកថានឹងនៅ
ស្រុកនេះហើយ ហេតុដូចម្ដេចក៏វិលទៅស្រុកបន្ទាយភ្នំពេញ
វិញ នាយជាក៏តបថា កាលដើមខ្ញុំបាទថាប្រុងនឹងនៅក្នុងស្រុក
នេះពិតហើយ បានជាលោះជីប្រាក់នេះដើម្បីជាកំឡាំងជួយរក
ទទួលទាន ឥឡូវនេះបងខ្ញុំបាទមានសំបុត្រប្រាប់មកថា ម្ដាយខ្ញុំ
បាទឯស្រុកនាយនោះមានជម្ងឺឈឺជាទម្ងន់ ឲ្យខ្ញុំបាទវិលទៅស្រុក
ជាឆាប់ ហេតុនេះខ្ញុំបាទទាល់គំនិតប្រាជ្ញាចំណែកជីប្រាក់គេក៏
មិនព្រមទៅជាមួយផង គេថារកប្រាក់ជូនខ្ញុំបាទវិញខ្លួនខ្ញុំបាទ

ម្នាក់ឯងបានជាដើរតាមមកផងនេះ ឯចៅប្រាក់ឆ្លើយសារឡើង
ថា អ្នកចូរអាណិតខ្ញុំបាទផង បើអ្នកមិនសង្គ្រោះខ្ញុំបាទហើយ
ខ្លួនខ្ញុំបាទឃើញជាគេយកទៅស្រុកបន្ទាយមិនខានឡើយឯចៅ
ទ្បចក៏ទទួលថាជួយ ទើបយកប្រាក់១០០បាទរាប់ឲ្យទៅដៃនាយ
ជា ហើយទារយកសំបុត្រដើមនោះ អំពីនាយជាៗក៏កែកោង
កុហកថា បាទទេកាលខ្ញុំបាទលោះចៅប្រាក់ពីម្ចាស់ដើមនោះ
ទើបបាន ៤ ៥ថ្ងៃពុំទាន់ធ្វើសំបុត្រទេ ថានឹងធ្វើហើយចៅប្រាក់
អង្វរខ្ញុំបាទថា ណាៗគង់តែនឹងចេញឆាប់ទេនឹងធ្វើសំបុត្របង
ថ្លៃសំបុត្រនោះថ្វី ហេតុនេះបានជាគ្មានសំបុត្រដើមនោះ អ្នក
កុំវង្វេងសចិត្តឡើយ មិនអីទេ យើងខ្ញុំនេះមិនអាចនឹងមកឆអ្នក
ផ្តេសផ្តាសឯណាបាន ស្រុកមានផ្ទឹមមានប្រមេទអ្នកអ្នកកុំ
សង្ស័យឡើយ ចៅទ្បុកក៏ស្ងៀមពុំមានថាអ្វីឡើយប្រគល់
ប្រាក់ ១០០ បាទឲ្យទៅនាយជាៗ បានប្រាក់ក៏វេចម្នីម្នា ហើយ
លាចៅទ្បចចុះមក ប្រើតែមុខសំឡក់ឲ្យចៅប្រាក់ ជាសញ្ញាថា
ព្រឹកស្អែកនេះសឹមចែកប្រាក់គ្នាឯផ្ទះអ្នកអ៊ូចុះ ហើយនាយជា
ដើរមកភូមិមាត់ស្ទឹងជាទីសំណាក់ខ្លួន នាយជាកើតលោភចេតនា
ប្រាថ្នាចង់បានប្រាក់នោះតែឯង ទើបកើតមិត្រទ្រុស្តដល់ចៅ



ប្រាក់ជាភឿនសំឡាញ់ គិតថាអញបានប្រាក់ហើយ គួរអញ
វិលទៅស្រុកជាឆាប់នឹងនៅដោយយឺយូរទៅ ក្រែងហេតុនោះ
នឹងកើតដល់ខ្លួន នាយជាគិតដូច្នោះហើយ ក៏ដើរទៅកាន់ផ្សារ
ស្វាយប៉ោ ប្តូរប្រាក់បាទបានជាប្រាក់រៀលធំចំនួនបាន១៦
រៀលហើយក៏ទិញបាយចំណីបារី ស្លា ជាស្បៀងតាមផ្លូវ ពេល
យប់នោះនាយជាក៏ចុះកប៉ាល់សាលុប ទៅឡើងកប៉ាល់ធំនៅ
ស្ទឹងបាក់ព្រាបាន វេលានាយជាទៅដល់ស្រុកឃ្លាំងស្បែកចែក
ចាយប្រាក់នោះតាមអំពើពុតពាលទៅ ឯចៅទ្បចនោះលុះព្រឹក
ឡើង និយាយនឹងចៅប្រាក់ថា ចាំពេលរួចបាយព្រឹកនេះ នឹងនាំ
គ្នាទៅធ្វើសំបុត្រឯសាសាក្នុងកំពែង ចៅប្រាក់នោះតាំងតែពី
នាយជាយកប្រាក់ថ្លៃខ្លួនអស់មក នៅមិនសុខឡើយចង់តែតាម
មកយកប្រាក់នោះអំពីដៃនាយជា ទើបនិយាយកុហកចៅទ្បុក
ថា អ្នកនឹងនាំខ្ញុំបាទទៅធ្វើសំបុត្រនោះ រឿងប្រាក់ថ្លៃសំបុត្រ
នោះកុំចាំអ្នកចេញឡើយ ប្រាក់ខ្ញុំបាទមានហើយ តែខ្ញុំបាទផ្ញើ
ទុកនឹងបងខ្ញុំបាទ ឯភូមិមាត់ស្ទឹងឯនោះ ចាំខ្ញុំបាទទៅយកពីគាត់
សិន ទម្រាំបាយឆ្អិនខ្ញុំបាទបានមកដល់រួចបាយ សូមទៅធ្វើសំបុ
ត្រឯសាលាក្នុងកំពែង ខ្ញុំសូមលាអ្នកទៅយកប្រាក់ពីបងសិន

ចៅឡុចក៏ជឿតាម បើកឲ្យចៅប្រាក់ទៅភូមិមាត់ស្ទឹង ចៅ
ប្រាក់បានឱកាស ក៏ខំដើរស្រូតត្រង់ទៅផ្ទះអ្នកអ៊ូ សួររកតួនាយ
ជាអ្នកអ៊ូក៏ប្រាប់ថា នាយជាបាត់ខ្លួនទៅតាំងពីថ្ងៃម្សិលមិញពុំ
ឃើញមកដេកដូចកាលពីមុនៗនោះទេ ចៅប្រាក់ធ្លាក់ចិត្តគិត
ថាអេះ អាជានេះបានប្រាក់ច្រើនហើយទំនងជាគេចវេះ មិន
ចង់ចែកអញទេដឹងចៅប្រាក់គិតហើយ តាំងដើរស៊ើបសួរដំណឹ
ងនាយជាតៗទៅ មានគេដឹងឮខ្លះគេក៏ប្រាប់ថា នាយជានោះ
ចំពោះជាចុះកប៉ាល់ទៅស្រុកវាហើយ ចៅប្រាក់ឮថា នាយជា
ទៅស្រុកដូច្នោះ ក៏កើតទោមនស្សតូចចិត្ត គិតខេវខឹងនឹងនាយ
ជាផ្ទាឃ្លាំងស្បែកក្រពេកព្រោះពុំសមដូចសេចក្ដីប្រាថ្នារបស់
ខ្លួន ម្ល៉ោះហើយចៅប្រាក់ក៏ដើរវេះពាត់គេចវេះ មិនឲ្យចៅ
ឡុចជានាយនោះឃើញឡើយ ឯចៅឡុចជាម្ចាស់ប្រាក់លុះដល់
ពេលបាយក៏ពុំឃើញរូបចៅប្រាក់មក ចៅឡុចកើតសេចក្ដីក្ដៅ
ក្រហាយ ក៏ដើរស៊ើបសួររកពួកចៅប្រាក់នោះតែវាល់ថ្ងៃវាល់
វេលា កន្លងទិវារាត្រីជាយូរថ្ងៃទៅៗ ថ្លែងឯក្មេងជាបាវលោក
សុភាទេស ដែលចៅប្រាក់ឲ្យឃ្វាលគោក្របីនៅដួស ជាជំនួស
ខ្លួននោះ លុះកន្លងយូរថ្ងៃមក ពុំឃើញចៅប្រាក់វិលទៅវិញ



ដូច្នោះស្បៀងអាហារក៏អស់ទៅ ថ្ងៃ១នោះក្មេងដែលទទួល
បញ្ញើឃ្វាលក្របីនោះក៏ទៅផ្ទះ ដើម្បីនឹងយកស្បៀងអាស្រ័យ
ទើបជំរាបលោកសុភាថា ចៅប្រាក់នោះវាប្រាប់ខ្ញុំថា មកស៊ី
ឈ្នួលគេបាន ២ ៣ថ្ងៃ ឲ្យខ្ញុំបាទនៅឃ្វាលក្របីចាំវា ឥឡូវនេះ
បាត់ខ្លួនចំនួន១៥ថ្ងៃនេះហើយ ពុំឃើញវិលទៅវិញឡើយ ពុំ
ដឹងជាទៅដំបន់ណា ខ្ញុំបាទនៅឃ្វាលតែម្នាក់ឯងទេ លំបាកពេក
ណាស់លោកសុភាទេសឮថា ចៅប្រាក់វេះវត់បាត់ខ្លួនជាយូរ
ដូច្នោះហើយ ក៏ចាត់ប្រើអ្នកបំរើឲ្យដើររកតួចៅប្រាក់ អ្នក
បំរើដើរស៊ើបរកទៅក៏បានទៅជួបនឹងចៅប្រាក់នៅតៀម
ចិន ទើបគេចាប់តួចៅប្រាក់មកជូនលោកសុភាទេស ៗ ក៏ឲ្យ
ដាក់ច្រវាក់លៀមចៅប្រាក់ប្រើឲ្យជំរះស្មៅ បោសសម្រាម
ផ្ទាលមុខផ្ទះលោកសុភា ៗ ឯចៅឡុចដើរតាមរកតួតែសព្វៗ
ថ្ងៃលុះថ្ងៃ១ ចៅឡុកដើរទៅស៊ើបរកឯផ្សារស្វាយប៉ោលុះ
មកដល់ភូមិផ្ទះលោកសុភា បែរមើលទៅស្រាប់តែឃើញចៅ
ប្រាក់ ជាប់ច្រវាក់លៀមបោសសម្រាមនៅមុខផ្ទះលោកសុភា
ចៅឡុចក៏នឹកថា ចៅប្រាក់នេះមានទោសអ្វីអេះ បានជាលោក
ដាក់ច្រវាក់វានេះគិតហើយ ក៏ដើរចូលទៅរកលោកសុភា ដល់

ហើយក៏អង្គុយលុតជង្គង់សម្ពះ ដោយខ្លួនជាអ្នកតូចធ្លាប់តោខ្លាចអ្នកធំ ជំរាបសួរថា "សូមមេត្តាអត់ទោសចុះចៅប្រាក់នេះកើតហេតុអ្វី បានជាព្រះតេជព្រះគុណដាក់ប្រទាក់វា? លោកសុភាប្រាប់ថា "ឱអ្នកអើយខ្ញុំមិនចង់និយាយទេ អាប្រាក់នេះពេញជាខូចខិលណាស់ខ្ញុំឯងឲ្យទៅឃ្វាលក្របីឯវាលស្រែក្រៅ វាមិននៅឃ្វាលក្របីឡើយ វាចេះតែដើរទេះពាត់ផ្តេសផ្តាសវិវណាស់ ហេតុនេះបានជាខ្ញុំឯងឲ្យដាក់ប្រទាក់វានេះឯចៅឡុចឮដូច្នោះហើយ ក៏ដឹងរឿងជាចៅប្រាក់នេះវាជាខ្ញុំលោកសុភាពិតប្រាកដ ខ្លួនទៅលោះវានោះខុសច្បាស់ហើយ ចៅឡុចទាល់ប្រាជ្ញាក៏អង្គុយស្ងៀមនៅ លោកសុភាក៏សួរថា ចុះអ្នកឯងត្រូវការអ្វីបានជាមកសួររឿងអាប្រាក់នោះ" ។ ចៅឡុចក៏ជំរាបតាមរឿងខ្លួន មិនដឹងជាចៅប្រាក់ខ្ញុំគេខ្លួនបានលោះវាបង់ប្រាក់១០០បាទ តាំងពីដើមដល់ចុង ជំរាបលោកសុភាសព្វប្រការ លោកសុភាក៏សើចហើយថា "មិនអីទេអ្នកឡុចខ្ញុំឯងបើកឲ្យ ចូរអ្នកយកប្រាក់២០០បាទមកលោះយកវាទៅចុះ" ។ ចៅឡុចក៏ទាល់គំនិតឆ្លើយថា "ខ្ញុំបាទជាអ្នកក្រ នឹងបានប្រាក់ពីណា២០០បាទនោះមកថែមលោះវាទៀត តែប្រាក់១០០បាទដែលបង់មុន



នោះគឺខ្ចីគេខ្ចីឯងផ្សំផងទេ" ។ លោកសុភាថា "បើដូច្នោះប្រាក់ដែលបង់នោះមិនខូចទេហើយ ហះនឹងចាំទារពីវានោះកាលណានឹងបាន ឲ្យអ្នកឯងចេញយកវាទៅចុះ សូមធ្វើសំបុត្រដាប់ជា៣០០បាទទៅ ។ ចៅឡុចក៏ទាល់ទញ់ចិត្តណាស់ អង្គុយគិតទៅក៏យល់ការ ទើបសួរទៅចៅប្រាក់ថា "អើចៅប្រាក់ អាដែងដែលវានាំឯងទៅលក់នោះ តើឈ្មោះអីវានៅឯណាសព្វថ្ងៃនេះ! ចៅប្រាក់ប្រាប់ថា "អានោះឈ្មោះអាជាជាតិជាជ្វា នៅស្រុកបន្ទាយភ្នំពេញឥឡូវវារត់ទៅស្រុកវាហើយ ប្រាក់នោះវាយកទាំងអស់ទៅពុំបានចែកខ្ញុំបាទទេ" ។ ចៅឡុចសួរសាំទៅទៀតថា" ចុះកាលវាមកនៅស្រុកយើងនេះ តើវាសំណាក់នៅផ្ទះអ្នកណាឯង? "បាទទាន វាសំណាក់នៅផ្ទះអ្នកអ៊ូនាងជា ភូមិផ្ទះនៅក្រោមភូមិលោកមហាថៃ" ។ ចៅឡុចឮដូច្នោះហើយ ក៏លាលោកសុភា ចុះម្នីម្នាទៅភូមិក្រោម ស៊ើបទីសំណាក់នាយជា នឹងមេស្រុកភូមិនោះ បានដឹងច្បាស់ថា អ្នកអ៊ូជាមនុស្សគប់គិតនឹងមនុស្សអាក្រក់ យកមនុស្សអាក្រក់ឲ្យសំណាក់នៅផ្ទះ ចៅឡុចក៏ធ្វើរឿងរ៉ាវប្តឹងយកអ្នកអ៊ូ ហើយទៅប្តឹងឯសាលាក្នុងកំពែង ។ ឯចៅក្រមទទួលពាក្យបណ្តឹងនោះមើលដឹងសេចក្តីហើយ ក៏ឲ្យ

ទៅកោះយកនាយអ៊ូមកជំនុំជំរះពិភាក្សាតាមពាក្យចោទ ៗ
អ្នកអ៊ូអាចឲ្យការកាត់បណ្តឹង ព្រោះចោអាងមេស្រុកជាបន្ទាល់
សំខាន់ ទាល់ប្រាជ្ញាក៏ទទួលសារភាពថាខ្លួនឲ្យសំណាក់គប់គិតពិត
មែន ៗ ទើបចៅក្រមកាត់ក្តីនោះឲ្យអ្នកអ៊ូសងប្រាក់អ្នកដើម
ចោទជាប្រាក់១០០បាទ អ្នកអ៊ូសូមសន្យា៣ថ្ងៃនឹងយកប្រាក់
នោះមកបង់ ហើយទៅផ្ទះតាមវេងខ្លួន លុះដល់កំណត់អ្នកអ៊ូ
យកប្រាក់១០០បាទទៅបង់សាលា ប្រគល់ឲ្យទៅដៃលួងស្រី
អញ្ជិតនោះ ជាអ្នកជក់អាភៀនពុំមានសេចក្តីអៀនខ្មាសយក
ប្រាក់នោះបាយ ទិញស្រាអាភៀនជក់ស៊ីទៅតាមអំណាចខ្លួន
ពាល ៗ លុះដល់ពេលល្ងាចចៅឡុចឡើងទៅចាំទទួលប្រាក់នោះ
តាមសញ្ញា ឯលួងស្រីអញ្ជិតឃើញចៅឡុចមកចាំយកក៏និយាយ
ថា ប្រាក់នោះនាយអ៊ូគេយកមកបង់ឲ្យហើយ តែខ្ញុំយកទៅទុក
ឯផ្ទះខ្ញុំឯនោះហើយ ឥឡូវនេះខ្ញុំឯងធុរៈនឹងការលោកម្ចាស់រវល់
ពេកណាស់ នឹងទៅយកឲ្យអ្នកឯងពុំបានចាំថ្ងៃខានស្អែកចុះ សូម
មកយក ចៅឡុចក៏ទាល់សំដីនៅស្ងៀមទើបលាលួងស្រីអញ្ជិត
មកផ្ទះវិញ លុះកន្លងទៅបានពីថ្ងៃ ចៅឡុចឡើងទៅផ្ទះលួង
ស្រីអញ្ជិតៗនោះ ឃើញចៅឡុចមកដល់ផ្ទះខ្លួន ក៏វេះគេច



ពួនលាក់ខ្លួនពុំឲ្យជួបនឹងចៅឡុចៗ នៅចាំអស់ចិត្ត តាំងពីព្រឹក
ដល់ល្ងាចក៏ពុំជួប ចៅឡុចរឹងតែរំខានពេកណាស់ មិនបានក៏វិល
ត្រឡប់ទៅផ្ទះវិញ ៗ លុះនៅយូរថ្ងៃទៅ ចៅឡុចក៏ឱស្សាហ៍
ឡើងយកប្រាក់នោះទៀតក៏ពុំបាន ស្រីអញ្ជិតចេះតែនិយាយ
កុហកទៅផ្សេងៗ ចៅឡុចទារយកប្រាក់ពុំបានរឹងតែព្រួយ
ចិត្តខ្លាំង ទញ់គំនិតក៏គិតធ្វើរឿងរ៉ាវក្លាយទោសលួងស្រីអញ្ជិត
នោះ ប្តឹងលោកកថាថនៗ លោកក៏ខឹងនឹងនាយស្រីអញ្ជិត
ព្រោះកោងឆរាស្ត្រ ទើបលោកឲ្យឃុំខាំងដាក់ទោសស្រីអញ្ជិ
តនោះ ៗ ឯចៅឡុចសោតក៏ពុំអាចប្តឹងទារយកប្រាក់នោះទៀ
តឡើយ ព្រោះស្រីអញ្ជិតនោះត្រូវក្តីហើយ ប្រាក់នោះក៏សាប
សូន្យអសាឥតការទៅហោង ៗ រឿងពាលយ៉ាងនេះឯងស្តាប់
មើលចុះ ចៅឡុចខូចប្រាក់នោះព្រោះពុំមានសតិសម្បជញ្ញៈ
ត្រិះរិះឲ្យល្អិតល្អ ការដែលឆោតលុះអំណាចពាលនោះ ព្រោះ
តែសេចក្តីប្រាថ្នា ប្រារព្ធនូវវត្ថុរឿយៗ ទើបបង្កើតជាផ្លូវ
មនុស្សពាលវាដើរចូលបាន បុរាណលោកថា ឯសេចក្តីឃ្លានបាយ
១ ឃ្លានទ្រព្យ១ ឃ្លានស្រឡាញ់១ ទាំង៣នេះជាភោគពាលគឺ
ជម្ងឺនេះមានដល់រូបណាហើយរូបនោះគង់នឹងឆោតមិនលែង

ហើយមនុស្សពាលវាចូលបៀតបៀនមិនខានឡើយ ព្រោះសេចក្ដីឃ្លានអ្នកស្រុកសន្សំទុកមករឿយៗហើយ ដូចយ៉ាងចៅពាលម្នាក់វាទៅបៀតបៀនលោកសង្ឃ ឲ្យបង់ប្រាក់៥០រៀល ឯងចាំស្ដាប់មើលចុះ អញនឹងសំដែងប្រាប់ថា៖

## រឿងលោកគ្រូចៅអធិការវត្តកោះ

កាលនោះមានបុរសម្នាក់វាដឹងថា លោកចៅអធិការវត្តកោះស្រុកទន្លេធំលោកនោះបរិបូណ៌ដោយលាភសក្ការៈច្រើនចំរើនចិត្តប្រព្រឹត្តទៅក្នុងលោក បង្កើតសេចក្ដីលោភរឿយៗ ។ ថ្ងៃ១បុរសពាលម្នាក់វាស្លៀកពាក់រៀបរយសុភាពរាបសា ប្រើអាការកិរិយាដូចជាឧបាសកអ្នករក្សាសីល ដែលមានសទ្ធាក្នុងព្រះពុទ្ធសាសនា ចូលទៅរកលោកចៅអធិការៗ ក៏ធ្វើបដិសណ្ឋារៈទទួលតាមសមគួរ ។ ចៅពាលក៏និយាយថា ខ្ញុំករុណានឹងគិតធ្វើបុណ្យម្ដាយក្នុងខែប្រាំងនេះឯគ្រឿងទេយ្យទានគឺត្រៃចីវរចំណែកខាងលោកឡើងខ្ញានមាតិកានោះ ក៏បានជាវគេស្រេចអស់ហើយត្រៃចីវរខាងលោកទេសនាសង្គាយនាត្រៃ៣ នោះក៏បានចាត់ចែងស្រេចអស់ហើយ នៅតែត្រៃចំណែកអភិធម្មនោះ ពុំទាន់ធ្វើនៅឡើយព្រោះបងប្អូនកូន ប្រពន្ធខ្ញុំករុណាពី



គ្រោះយល់ព្រមគ្នាថា លោកឡើងព្រះអភិធម្មនោះគួរដល់ព្រះតេជព្រះគុណជាម្ចាស់នេះ ខ្ញុំករុណាមកនេះសូមអារាធនានិមន្តព្រះតេជព្រះគុណឡើងព្រះអភិធម្ម នាំផ្លូវឲ្យមាតាខ្ញុំករុណាក្នុងការបុណ្យនោះឲ្យទាន ឯត្រៃសម្រាប់ប្រគេននោះ ចាំមកមើលត្រៃព្រែរបស់ព្រះតេជព្រះគុណឯនេះ ជាព្រះគុណសព្វព្រះហឫទ័យព្រែបែបណា ក៏នឹងទិញព្រែខ្នាតនោះឲ្យត្រូវព្រះហឫទ័យសូមទានព្រែត្រៃគំរូមើលនឹងបានចាត់ចែងតាម ឯលោកចៅអធិការឮចៅពាលពោលត្រូវចិត្តដូច្នោះហើយ ក៏តបថាចំរើនពរ ត្រៃព្រែអាត្មាភាពមានខ្លះដែរ តែមិនសូវត្រូវចិត្តអាត្មាប៉ុន្មានទេ បើឧបាសកមានសទ្ធាយ៉ាងនេះមានតែទៅមើលត្រែងផ្សារត្រើយម្ខាង ព្រែយ៉ាងណាក៏មានសូមទានបើដូច្នោះ និមន្តព្រះតេជព្រះគុណជូនខ្ញុំព្រះករុណាទៅមើល បើត្រូវព្រះហឫទ័យព្រែបែបណា ខ្ញុំព្រះករុណានឹងជាវបែបនោះមកធ្វើព្រគេនចំរើពរ បានមិនអីទេថាហើយចៅអធិការហៅប្រើកូនសិស្សឲ្យទៅរៀបទូកក្ដារ ឯក្មេងកូនសិស្សក៏នាំគ្នារៀបទូកបញ្ចុះលោកគ្រូនឹងចៅពាលនោះចែវឆ្ពោះត្រង់ទៅដល់ត្រើយម្ខាងទំនងយ៉ាងផ្សារស្រុករការកោងទើបចាត់ឲ្យអ្នកចែវនៅចាំទូក

លោកចៅអធិការក៏នាំចៅពាលនឹងក្មេងស្លាយយាមឡើងទៅ
ផ្សារ ដើរទៅដល់ផ្ទះចិនៗ ក៏និមន្តឲ្យចូលទៅចិនឃើញលោក
គ្រូធំមកផ្ទះខ្លួន ក៏ត្រេកអររៀបអាសនានិមន្តលោកឲ្យគង់
ហើយសួរថា លោកគ្រូម្ចាស់និមន្តមកដោយត្រូវការអ្វី?។

ចំរើនពរអាត្មាភាពជូនឧបាសកនេះមកទិញព្រែធ្វើត្រែ
ព្រែសៀងហែយ៉ាងល្អនោះ តើជាមានខ្លះដែរឬអ្នកដង្ហៅ។

ករុណាម្ចាស់មានខ្លះដែរលោកគ្រូម្ចាស់ត្រូវការខ្ញុំករុណានឹង
យកមកប្រគេនទតមើល។ ចំរើនពរយកមកមើលអ្នកដង្ហៅ។
ចិនក៏ទើព្រែច្រើនក៏ស្រាយលាតឲ្យលោកគ្រូនឹងចៅពាលនោះ
មើល លុះរើសមើលទៅបានព្រែល្អ២កី លោកចៅអធិការក៏
និយាយទៅកាន់ចៅពាលនោះថា ព្រែ២កីនេះត្រូវចិត្តអាត្មាហើ
យបើអ្នកត្រូវការនឹងសាងត្រែ គប្បីយកព្រែខ្នាតនេះចុះ។
ចៅពាលក៏តបថា ករុណាម្ចាស់បើព្រះតេជព្រគុណសព្វព្រះហ
ឫទ័យហើយ ខ្ញុំករុណានឹងជាវចុះថ្លៃថ្នូរប៉ុន្មានអ្នកដង្ហៅ។ ចិនក៏
កាត់ថ្លៃ៥០រៀលជាការដាច់ខាត ចៅពាលក៏ថាបានខ្ញុំបានយក
ហើយធ្វើម្តេចឯងប្រារព្វធ្វើបុណ្យ ចំពោះព្រះតេជព្រះគុណ
ហើយ ថ្លៃយ៉ាងណាក៏ចេះតែយក តែប្រាក់ខ្ញុំជាប់មកនេះតែ២០



រៀលទេ. មិនគ្រប់គ្រាន់បើដូច្នេះសូមនិមន្តព្រះគុណនៅគង់រង់
ចាំខ្ញុំព្រះករុណានឹងទៅយកប្រាក់អំពីបងនៅភូមិលើមកបង្គ្រប់
លោកចៅអធិការក៏ថាចំរើនពរ អញ្ជើញទៅឲ្យឆាប់ចុះអាត្មា
នៅរង់ចាំនៅនេះ ឯចៅពាលក៏លាលោកនឹងចិនចេញទៅភូមិ
លើ ដើរអមទៅកំពង់ដែលចតទូក ហើយប្រាក់កូនសិស្សដែល
ចែវទូកមកនោះថា ឥឡូវព្រះតេជព្រះគុណប្រើឲ្យយើងនាំចៅ
ឯងទៅយកប្រាក់៥០រៀលឯកុដិលោក ឯពួកកូនសិស្សទាំង
នោះក៏ជឿតាម ទើបចុះចែវទូកឆ្លងមកដល់វត្តកោះហើយ ក៏
ឡើងទៅប្រាប់លោកសង្ឃដែលរក្សាកុដិកាន់កូនសោនោះថា
ព្រះតេជព្រះគុណប្រើឲ្យមកយកប្រាក់៥០រៀល ទៅឲ្យថ្លៃ
ទំនិញចិន ឯលោកសង្ឃរក្សាកុដិក៏ជឿ ទើបចាក់សោហិបបើក
យកប្រាក់៥០រៀលប្រគល់ឲ្យទៅដៃចៅពាលៗ ក៏នាំកូន
សិស្សចុះចែវទូកឆ្លងវិលទៅត្រើយវិញ លុះដល់ហើយចៅ
ពាលថា ចៅឯងទាំងអស់គ្នានៅចាំទូកចុះ ខ្ញុំឯងនឹងយកប្រាក់
នេះទៅប្រគេនលោកគ្រូ ថាហើយក៏ឡើងម្នីម្នាចេញទៅទិស
បូព៌ា មានមុខឆ្ពោះត្រង់ចូលព្រៃយកប្រាក់នោះទៅកែខៃបរិ
ភោគតាមប្រាថ្នា។

ថ្ងៃឯងលោកចៅអធិការនៅរង់ចាំចៅពាលតាំងតែពីពេលថ្ងៃត្រង់ លុះដល់ពេលល្ងាចចិនក៏បំរុងទឹកតែស្កូវសអស់ ៣ ៤ បាន់ក៏ពុំឃើញចៅពាលនោះមក ម្ល៉ោះហើយរំខានព្រះហឫទ័យខ្លាំង ក៏ឲ្យចិននោះយកតែព្រទៅទុក ចំរើបពរលាចិនចុះមកកាន់កំពង់ទឹកហៅសិស្សឲ្យចែវទូកឆ្លងវិលទៅវត្តកោះ តាំងពោលជេរចៅពាលនោះថា អាឱបាសកចង្រៃឲ្យឯងជូនមកទិញតែព្រធ្វើត្រៃ តថ្លៃចិនស្រេចហើយវាវេះទៅឯណាបាត់ ឲ្យឯងលំបាកចាំផ្លូវវាអស់១ថ្ងៃទទេទៅ ឯកូនសិស្សអ្នកចែវទូកឮលោកគ្រូពោលដូច្នោះ ក៏ទូលថាឱបាសកនោះ គាត់មកឲ្យពួកយើងខ្ញុំនេះចែវទូកបញ្ជិះគាត់ឆ្លងទៅយកប្រាក់៥០រៀល អំពីលោកបងដែលចាំកុដិ គាត់ថាព្រះតេជព្រះគុណប្រើឲ្យទៅយកប្រាក់នោះបានហើយ គាត់ក៏ឡើងពីកំពង់ទៅ ថាយកប្រាក់ទៅប្រគេនព្រះតេជព្រះគុណឯផ្សារ ព្រះករុណាមិនឃើញគាត់ទៅដល់ ព្រះតេជព្រះគុណទេឬ លោកចៅអធិការថា ឱអីចុះអាអញមានប្រើឲ្យវាទៅយកប្រាក់កាលណា វាលាអញមកថាវាទៅយកប្រាក់អំពីបងប្អូនវា ឯភូមិលើទេ នេះវាប្រែថាអញប្រើវាមកយកប្រាក់ឯកុដិអញវិញ អើបើដូច្នោះវាអស់ហើយ



ប្រាក់អញនោះ អាឯងទាំងអស់គ្នាមិនគួរទៅជឿវា ខំចែវទូកពីរបីត្រឡប់ប្រាក់ក៏បង់ថង់ក៏ដាចហើយពួកអ្នកចែវទូក នឹងមិនជឿវាឯណាបានព្រោះវាឡើងទៅជាមួយនឹងព្រះតេជព្រះគុណ លោកចៅអធិការក៏ទាល់សំដីនឹងពួកកូនសិស្ស ថាអើបើដូច្នោះខំចែវទៅឲ្យឆាប់ ត្បិតពេលជិតយប់ហើយក្រែងត្រូវខ្យល់ព្យុះខ្លាំង ផាត់មកលិចទូកក្តារណាអា អ្នកចែវក៏គ្នាខំចែវទូក ត្រាតែដល់កំពង់វត្ត ល្មមពេលម៉ោង៨ ៩យប់ លោកចៅអធិការទៅដល់កុដិហើយ ក៏រឹតតែកើតទោសោបន្ទោសទៅលោកដែលនៅចាំកុដិថា មិនគួរទៅជឿមនុស្សនឹងដល់ចាក់សោយកប្រាក់ឲ្យទៅ អាមនុស្សពាលនោះសោះលោកដែលនៅចាំកុដិឆ្លើយថា មិនជឿឯណាបានព្រោះក្មេងចែវទូកវាមកផង លោកគ្រូក៏ទញ្ញ់ទាល់នៅៗនោះទៀត មានសេចក្តីពុំសប្បាយ ដោយចាញ់កលមនុស្សដោយប្រការយ៉ាងនេះ ៗ

**ចប់រឿងលោកគ្រូវត្តកោះអស់សេចក្តីត្រឹមនេះ។**

ពាក្យក្មេងវាច្រៀង សង្ឃអើយលោកសង្ឃ តែមានចំណង់គងបង់បច្ច័យ លោកគ្រូវត្តកោះ ព្រោះត្រេកនឹងត្រៃ អាពាលចង្រៃ វីបានហាសិប ៗ

រឿងពាលនេះមានឧបាយកលបញ្ឆោតច្រើនប្រការណាស់ ឯស្ដាប់មើលចុះតែពុំមានប្រាជ្ញាត្រិះរិះតាមអាការវាចេញនោះ ហើយ ក៏គង់ធ្លាក់ចុះក្នុងកលវាដូចពណ៌នាមកនេះឯង ៗ

មានមនុស្សពាល១ទៀតវាប្រើឧបាយតែពីចម្ងាយផ្ទះមកឲ្យមនុស្សជឿបាន ដូចនិទានលោកចៅអធិការមួយអង្គ គង់នៅវត្តស្រុកខាងលើជ្រោយចង្វានេះឯងទៅចុះជឿមនុស្សពាលឲ្យខូចប្រាក់៨០ រៀលនិទាននោះថា កាលនោះលោកចៅអធិការមានក្ដីប្រាថ្នានឹងធ្វើព្រះវិហារ បានឃោសនាឧបាសក ឧបាសិកាជើងវត្តបានប្រាក់៨០ រៀលអាចារ្យវត្តចាត់ទុកនៅដៃលោកចៅអធិការ ប្រាថ្នានឹងទិញឈើធ្វើព្រះវិហារ ៗ

## រឿងលោកសង្ឃសាងវិហារ

ថ្ងៃ១ មានបុរសពាលម្នាក់វាដឹងថា លោកគ្រូនោះមានប្រាក់ ៨០រៀល ទើបវាតែកាយស្លៀកពាក់ហាក់ដូចជាដំឡៅឈើ មានចៅពាលម្នាក់ទៀត ធ្វើជាកូនឈ្នួលដើរតាមក្រោយ ចូលទៅវត្តនោះដល់ហើយវាឡើងទៅឯទីវិហារចាស់ ធ្វើកិរិយាពុំនាំពាក្យចរចានឹងអ្នកណា១ឡើយវាឲ្យកូនឈ្នួលនោះទាញខ្សែរម្ដាង វាទាញម្នាងវាវាស់ទទឹងបណ្ដោយវិហារហើយវាធ្វើ



ជាសរសេរខ្នាតដាក់សៀវភៅ វាស់ព្រះវិហារនោះទៅមក តែពីរនាក់នឹងកូនឈ្នួល ៗ ឯបណ្ដាភិក្ខុសាមណេរទាំងឡាយ ឃើញអាពីរនាក់ទាញខ្នាតវាស់ព្រះវិហារខ្លួនដូច្នោះ ក៏សង្ស័យទីទៃៗ លោកខ្លះទៅពិតទូលលោកចៅអធិការៗ ក៏នឹងសង្ស័យ ថា ឧបាសកគេមកវាសវិហារយើងនេះហេតុអ្វីអេះ! ទំនងគេនឹងចង់ជួយសាងវិហារយើងដឹង បើដូច្នេះគួរតែទៅស៊ើបសួរមើលឲ្យដឹងការ ថាហើយលោកចៅអធិការទៀបអាត្មាសុភាពដើរទៅរកចៅពាលនោះ ឯចៅពាលយល់លោកគ្រូចៅអធិការមកដល់ ក៏ធ្វើដាឈប់វាស់តាំងសរសេរកត់ដាក់សៀវភៅ ហើយបែរទៅលើកដៃសម្ពះថា លោកម្ចាស់នេះឬជាចៅអធិការវត្តនេះ? ចំរើនពរ អាត្មាភាពនេះឯងជាចៅអធិការ ករុណាម្ចាស់ព្រះវិហារនេះ ជាមានលោកអ្នកឯណាគិតធ្វើហើយឬពុំមានទេ? ចំរើនពរ ពុំមានលោកអ្នកឯណាមានសទ្ធាធ្វើទេ តែរូបអាត្មាភាពនេះ ឃោសនាញាតិញោមជើងវត្តបានបច្ច័យបន្តិចបន្តួច នឹងធ្វើពុំទាន់បានចំរើនពរ ឱបើដូច្នោះករុណាម្ចាស់ប្រោសមេត្តាខ្ញុំករុណាសាងទៅដឹងវិហារនេះ ព្រោះខ្ញុំព្រះករុណាជាដំឡៅក្បូនឈើបាននាំមកហើយ តែពុំទាន់ដល់ទីនេះនៅ

ឡើយខ្ញុំព្រះករុណាចុះមកមើលទី នឹងដាក់ក្បូនឈើជាមុនឥឡូវ
ឃើញទីកំពង់វត្តលោកគ្រូម្ចាស់នេះទីទូលាយសប្បាយ គួរដាក់
ចំណាយបានមួយទៀតរឿងឈើធ្វើវិហារនោះ ខ្ញុំព្រះករុណា
បានចាត់មកនឹងក្បូនជាស្រេច បើខ្វះខាតទៀត សូមទៃលក
យកឈើក្បូននោះថែមថយ ត្រាតែឲ្យគ្រប់ករុណាម្ចាស់កុំព្រួយ
ព្រះទ័យឡើយ សូមតែកំឡាំងជួយលើកជួយដាក់សែងលី
ប៉ុណ្ណោះចុះ ត្បិតខ្ញុំព្រះករុណាតិចគ្នានឹងធ្វើៗ "ចំរើនពរ បានទេ
ឯខាងកំឡាំងសែងលីនោះ ជាភារៈលើអាត្មាភាពចុះ"ៗ "ករុណា
ម្ចាស់បើលោកគ្រូម្ចាស់ជួយផងនោះ ការនោះយល់ជាកើតឆាប់
"ៗ ចៅពាលនិយាយប្រៀបប្រាយបណ្ដើរ ធ្វើជាប្រើអាការៈ
បន្តិចបើកនាលិកាដក់មើលម៉ោង បន្តិចធ្វើជាទើយកក្រដាស
ប្រាក់អំពីថង់ស្បែកមករាប់ លោកចៅអធិការឃើញចៅពាល
វាសំដែងចេញដូច្នោះក៏រឹតតែជឿពេញចិត្ត ហើយថាចំរើនពរ
អញ្ជើញញោមដង្ហោទៅឯកុដិសិនៗ ករុណាមិនអីទេៗថា
ហើយក៏នាំកូនឈ្នួលទៅឯកុដិលោកចៅអធិការ ៗ ឲ្យក្មេងយក
កន្ទេលថ្មីខ្នើយថ្មី រៀបទទួល ហើយអញ្ជើញចៅពាលឲ្យអង្គុយ
សមគួរហើយ ឲ្យក្មេងសិស្សដាំតែល្អស្ករល្អតាងលៀងចៅពាល



នោះ ឯចៅពាលក៏សន្ទនាប្រស្រ័យនិយាយពីរឿងធ្វើវិហារ
នោះជាអនេកបរិយាយផ្សេងៗ លោកចៅអធិការក៏រួស
រាយសប្បាយចិត្ត ព្រោះត្បិតត្រូវអារម្មណ៍ដែលសន្សំមកយូរ
ហើយលុះពេលល្ងាច ចៅពាលក៏ថ្វាយបង្គំលាចុះម្ជីម្នាដើរចេញ
មកបន្តិច ក៏គេចចូលទៅវិញហើយថា "ករុណាម្ចាស់ឥឡូវនេះ
កូនឈ្នួលវាសូមបើកប្រាក់ខ្ញុំករុណាមានតែក្រដាស់ប្រាក់១០០
នឹងបែកចាយពុំបាន សូមទានប្រាក់ដែលឃោសនានោះ សូមខ្ចី
ចាយសិន ទំរាំតែខ្ញុំព្រះករុណាទៅប្ដូរពីផ្សារបាន ឬលោកគ្រូ
ម្ចាស់មិនជឿចិត្ត ក៏សូមនិមន្តយកប្រាក់ក្រដាស់១០០ របស់ខ្ញុំ
ករុណាទុកជាសំខាន់ចុះ"ៗ ឯលោកចៅអធិការនោះ លុះអំណាច
ជឿផងជាប់ហើយ ទើបឆ្លើយថា "ចំរើនពរបានទេ"ៗ ថាហើយ
ក៏ចូលទៅក្នុងកុដិចាក់សោហិបបើកយកប្រាក់៨០រៀលចេញ
មកឲ្យទៅដៃចៅពាលៗ ក៏ទទួលមួយរំពេចរវិចដាក់ក្នុងថង់
ស្បែកហើយថា "ករុណាម្ចាស់យកប្រាក់ក្រដាស១០០របស់ខ្ញុំ
ព្រះករុណាទុកជាដំណាងឬដូចម្ដេច"ៗ "ចំរើនពរមិនអីទេ
អញ្ជើញយកទៅចុះ ទុកនៅលើញោមដង្ហោក៏ដូចជាទុកនៅ
លើអាត្មាភាពដដែល ការវិហារសីមានោះ ក៏ស្រេចនៅលើ

ញោមដង្ហៅហើយ អញ្ជើញទៅហើយសូមមកវិញកុំយូរពេក"ៗ

ចៅពាលបានឱកាសហើយក៏ម្នីម្នាចេញទៅខាងផ្លូវមាត់ទន្លេ ដើរទៅកាន់ភូមិក្រោម ត្រដល់ភូមិជ្រោយចង្វា ចៅពាលនាំគ្នាចុះនាវា (គឺទូកដ) ឆ្លងដលើត្រើយក្រុងភ្នំពេញ តាំងទិញស្រាបាយចំណីឬអាភៀនញៀន ដល់ចូលរោងនាងកិន្នរីស្រីផ្កាមាសដោយអំពើពាលហោងៗ ឯលោកចៅអធិការនោះនៅរង់ចាំមើលក្បួនឈើជាយូរថ្ងៃ ក៏ពុំឃើញមានធ្លាក់មកដល់១ឡើយ ម្ល៉ោះហើយរឹងជាទុក្ខទោមនស្សនៅ លុះកន្លងខែ១-២ទៅ ក៏កើតវិប្បដិសារី រំលឹកឃើញសេចក្ដីដែលខ្លួនឆោតខ្លៅឲ្យអាពាលដង្ហៅខ្ចីប្រាក់៨០ ទៅស៊ីបាត់ម្ដង ទាំងពួកញាតិញោមផង ក៏នាំគ្នាតឹកកងស្ដីបន្ទោសលោកចៅអធិការថា "លោកឥតប្រាជ្ញាស្មារតី ទៅជឿមនុស្សពាលអប្រិយឲ្យវាបញ្ឆោតយកប្រាក់អស់ ខានសាងព្រះវិហារ"ៗ ខ្លះក៏អស់សទ្ធា លែងចេញប្រាក់ចូលឃោសនាទៀតលោកចៅអធិការ ក៏រឹងជាទុក្ខសល់សែនណែនឱរាព្រោះពុំសមក្ដីប្រាថ្នា ដោយប្រការយ៉ាងនេះហោងៗ

ចប់រឿងសង់ព្រះវិហារ។



ពាក្យក្មេងវាច្រៀងថា ពាលអើយចៅពាល ចេះវាស់វិហារឲ្យសង្ឃសង្ស័យ សង្ឃសាងវិហារ មានមារចង្រៃ កន្លងវិស័យបង់ប៉ែតសិបរៀល ៗ

អើរឿងពាលនេះ ឯងស្ដាប់មើលចុះសុទ្ធសឹងមានឧបាយកលផ្សេងៗ ធ្វើឲ្យអ្នកស្រុកទាំងលោកសង្ឃនូវឧបាសកឲ្យលុះអំណាចវា បាននូវសេចក្ដីក្ដៅក្រហាយដូចបាននិយាយមកនេះ ហេតុនោះទើបថាមនុស្សពាលនេះ គួរខ្លាចណាស់ពាលនេះមានពុតអំពើធ្វើពុំតែម៉្យាងទេ សឹងមានច្រើនយ៉ាងណាស់ពុំឈ្នះនឹងពណ៌នា មានពាលខ្លះប្រើមារយាទយ៉ាងស្និទ្ធ ពាលខ្លះប្រើអំណាចកាច់កិនសង្កត់កំហែង លក់ទ្រព្យអ្នកស្រុក ដោយអាងខ្លួនថាជាញាតិនឹងអ្នកធំៗ

## រឿងឧកញ៉ាញៀនអាភៀន

មានចៅពាលម្នាក់ទីជាឧកញ៉ា ជាព្រះញាតិនឹងសម្ដេចព្រះបរមខត្តិយា ឧកញ៉ានោះជក់អាភៀនញៀនពេញកំឡាំងតែអស់ប្រាក់កាលណា វាក៏នាំបណ្ដាកូនក្មួយបាវព្រាវ ចុះទូកគែហ៊ៅចែវត្រាច់ទៅតាមទន្លេធំដល់ភូមិណា ស្រុកណាហើយវាឲ្យអាបាវព្រាវនោះឡើងកាប់ចេកកាប់អំពៅ បេះផ្លែឈើ គឺផ្លែ

ត្រសក់ ឱ្យឡើក ដេញចាប់មាន់ទារបស់រាស្ត្រយកជាប្រយោជន៍
ខ្លួនវា ថ្ងៃ១នោះ ចៅឧកញ៉ាឲ្យបាវចែវទូកទៅចតទៀប
កំពង់ភូមិស្រុករកាទ្វារ អាបាវវានាំគ្នាឡើងទៅកាប់ចេករបស់
តាក្រែសរញីមៗពុំបាននៅៗ តែយាយជាប្រពន្ធ អស់ពួកនោះ
ភាតប្បាត់កាប់ចេកជាង១០ស្ទុង ហើយវានាំគ្នាសែងលីមកដាក់
ទុក នៅសល់ចេក១ស្ទុងពុំយក ព្រោះចេកនេះនៅខ្ចីណាស់ គិត
ហើយយាយនោះ លើកយកចេកនោះដាក់ទៅលើរានហាល ។

ដល់ក្រោយ អាបាវម្នាក់វាដើរចូលទៅបានឃើញចេកដែល
កាប់នៅលើរានហាលយាយ ទើបវាភ្លែងថា "យាយឯងនេះម្តេច
ហ៊ានលួចចេកលោកនាយយើងទៅប្តឹងលោកនាយឲ្យជំរះចោរ
លួចចេកនេះហើយ" ។ យាយម្ចាស់ចេកឆ្លើយថា ឱកូនអើយ!
ម្តាយនេះលួចចេកកូនឯងកាលណា ម្តាយស្មានថាចេកនេះវាខ្ចី
ពេកស្មានឯងកាប់មកក្រែងប្រឡំថាចាស់មិនយកទៅ ចោល
នៅក្នុងទីនេះយ៉ាងជាកូនមិនត្រូវការដឹង បានជាម្តាយលើកដាក់
មកលើរានហាលនេះ ឥឡូវបើកូនត្រូវការហើយ ក៏អញ្ជើញ
ទៅចុះម្តាយនឹងថាអី ។ អានេះមិនស្តាប់វាទៅប្តឹងឧកញ៉ានាយវា
ឯនាយនោះនឹងបាវវាដឹងគ្នា ទើបឲ្យពួកវាឡើងទៅកោះ យក



យាយនោះមក យាយនោះភិតភ័យក្រៃពេក ដល់ហើយវាកាត់
លក់យាយនោះជាប្រាក់៣ណែន យាយនោះសូមអង្វរទៅត្រឹម
១ណែន ១កំណាត់ យាយម្ចាស់ចេកក៏បង់ចេក១០ស្ទុង នឹងប្រាក់
១ណែន ១កំណាត់ ទៅដៃឧកញ៉ាពាលនោះឯង ។

ឯងស្តាប់មើលទៅចុះស្រុកខ្មែរយើងនេះ ពីដើមមានមន្ត្រី
ពាលដើរបៀតបៀនរាស្ត្រ ឲ្យរាស្ត្រក្តៅក្រាយផ្សេងៗ ដូច
យ៉ាងឧកញ៉ាពាលដែលវាកំហែងយាយម្ចាស់ចេកនៅស្រុករកា
ទ្វារជាប់គ្នានឹងស្រុកព្រែកពោធិ៍នោះឯងទាល់តែរាស្ត្រស្រុក
ទន្លេធំ រអាខ្លាចអំណាចឧកញ៉ាពាលនោះ តែឃើញទូកតែ
ហៅចៅឧកញ៉ាពាលនោះចតនៅកំពង់ភូមិណាហើយ ក៏មិនហ៊ា
ននិយាយថាអ្វីឡើយ ទោះជាពួកនោះកំហែងកាប់ចេក កាប់អំ
ពៅឬដេញចាប់មាន់ទាក្តី ក៏ពុំហ៊ានហាមឃាត់ថាអ្វីឡើយ ។

ឯអំពើចៅឧកញ៉ាពាលកំហែងលក់រាស្ត្រនោះមិនតែ
ប៉ុណ្ណោះទេ សឹងមានច្រើនប្រការទៅទៀត យើងសំដែងតែជា
ន័យសង្ខេបប៉ុណ្ណោះ ឲ្យឃើញថាពាលនេះវាប្រើឧបាយកល
កោងបញ្ឆោតកុហកបោកប្រាសខ្លះ វាប្រើកំហែងលក់ទ្រព្យដោយ
អំណាចវា ដែលវាជាមន្ត្រីអាងខ្លួនជាធំ ជាព្រះញាតិវង្សពង្សា

និងមហាក្សត្រខ្លះ ហេតុនោះទើបថាខ្លាចអ្វីមិនស្មើខ្លាចពាលកាចអ្វីមិនស្មើកាចមនុស្សពាល មនុស្សមានអំណាចនឹងគិតបៀតបៀនបុគ្គលណាហើយ ទោះមនុស្សនោះមានប្រាជ្ញាឆ្លាស់យ៉ាងណា នឹងគិតកែឲ្យផុតពីមនុស្សពាល ដែលមានអំណាចនោះគេចទៅពុំបាន ព្រោះមនុស្សពាលយកយសសក្តាជាអំណាចមកគ្របសង្កត់បំបាត់មាត់អ្នកតូច មិនឲ្យហើបហាថាអ្វីបានដូចបុរាណថា "ពាលប្រើអំណាចប្រាជ្ញតោងប្រាសចេញ"។

មួយទៀតថា ជាតិអ្នកតូចទោះមានប្រាជ្ញាចេះគេចកែក៏គេចកែបានក្នុងវារៈ ១-២ ដងតែបើពាលព្យាយាមមនឹងយាយីហើយ គេចទៅទៀតពុំរួចឡើយដូចនិទានកូនចៀមត្រូវឆ្កែព្រៃវាកំហែងចាប់ស៊ីនោះឯង។

## រឿងកូនចៀមនឹងឆ្កែព្រៃ

មានកូនចៀម១ចុះទៅផឹកទឹកជ្រោះ កាលនោះមានឆ្កែព្រៃ១ចុះទៅផង បានឃើញកូនចៀមនោះហើយ កើតក្តួចចង់ចាប់ស៊ី តែឆ្កែនោះគិតថាការនឹងកំហែងចាប់ស៊ីតែម្តងទៅក៏បាន ប៉ុន្តែហាក់ដូចជាមិនអស្ចារ្យចាំរកទោសវាឲ្យឃើញសិនគិតហើយឆ្កែព្រៃស្រដីកំហែងទៅថា រ៉ឺយអាកូនសត្វនេះម្តេច



ឯងក៏ខូចខិលម៉្លេះ គួរឬមកកូរទឹកឲ្យល្អក់អស់ រកតែឃើញនឹងផឹកផងពុំបានហះ។

ឯកូនចៀមឮឆ្កែព្រៃពោលចាប់ទោសដូច្នោះ ក៏តបថាខ្ញុំបានទទួលទានទឹកនៅក្រោមលោកទេតើ ទឹកល្អក់ឯណាដែលហូរប្រាសទៅខាងលើវិញនោះលោកនៅខាងលើខ្ញុំបាទយ៉ាងនេះ។

ឆ្កែព្រៃទាល់ប្រាជ្ញា ទើបរកកលចាប់ទោសឯទៀតវិញក្លែងចោទថា "អើពីឆ្នាំទៅមិញឯងដើរនិយាយដើមអញៗតែរកទេតើ"។ "បាទលោកបើគិតទៅរូបខ្ញុំបាននេះ មិនទាន់ទាំងកើតផងបើជាកើតសោតក៏នៅពុំទាន់ចេះនិយាយផង ហេតុម្តេចលោកមកចោទខ្ញុំបានថា ដើរនិយាយដើមលោកពីឆ្នាំទៅមិញនោះ"។ ឆ្កែព្រៃទាល់ប្រាជ្ញារកកលមួយទៀតកំហែងទៅថា "អើបើអាឯងមិននិយាយព្រោះនៅតូចទន់ បើដូច្នោះគឺបងអាឯងនិយាយដើមអញ"។ "ខ្លួនខ្ញុំបាទនេះ កើតជាកូនដំបូងក្នុងឧទរនៃមេខ្ញុំបាទនេះ បងខ្ញុំបាទនឹងមានកាលណាគឺខ្ញុំបាទនេះហើយជាកូនច្បង ហេតុម្តេចលោកមកចោទខ្ញុំបាទថា បងខ្ញុំបាននិយាយដើមលោកដូច្នេះ"។

"ឱបងអាឯងគ្មានសោះហះ បើដូច្នោះម៉ែឪជីដូនតាអាឯង

និយាយដើមអញ្ចហើយ"ៗ

កូនចៀមឮឆ្កែព្រៃចោទសេចក្តីតោងមិនដល់នឹងគេចចែក មិនដល់ដូច្នោះ ក៏ពុំអាចឆ្លើយតបបាន ទើបឈប់ស្ងៀមនៅឆ្កែព្រៃក៏ស្ទុះទៅចាប់កូនចៀមនោះប្រហារបរិភោគក្នុងកាលនោះឯងៗ

ពាក្យឆ្កែព្រៃចោទចាប់ទោសដល់ម៉ែឪ ជីដូនជីតានេះជាពាក្យធ្ងន់លើសប្រមាណទោះប្រាជ្ញាពោធិសត្វគង់គេចចែកទៅមិនផុត នរណាឡើយក្នុងលោកនេះដែលគ្មានមាតាបិតាជីដូនជីតានោះ សឹងមានគ្រប់រូបទាំងអស់ច្បាប់បញ្ញត្តិថា នរណាមានទសទណ្ឌកម្មហើយត្រូវច្បាប់ស៊ីដល់កូនចៅដែលកើតក្រោយផង ដូចច្បាប់ក្នុងស្រុកលើ គេបញ្ញត្តិថាបើមានអ្នកណាចេះធ្មប់ចេះអំពើព្រាយ ហើយមានគេទៅប្តឹងដល់មេកន្ត្រាញ ជាមេស្រុកនោះមេកន្ត្រាញត្រូវមានអំណាច ឲ្យទៅកោះចាប់យកអ្នកដែលគេចោទនោះមកជំរះពិភាក្សា បើជំរះទៅយល់មែនដូចពាក្យគេចោទហើយ ច្បាប់ត្រូវសម្លាប់ពូជនោះអស់៧សន្តានដោយហោចទៅតែទារកបៅដោះក៏ឲ្យសម្លាប់ទាំងអស់ៗ

មួយទៀតបើនរណាពួកណាប្រទូស្តគឹក្សត់ផែនដីក្តីឬ ទទឹង



រឹងរូសតអាជ្ញាមហាក្សត្រក្តី ច្បាប់ត្រូវប្រហារជីវិតទាំងត្រកូល ឯពួកញាតិពូជនោះ ត្រូវទំលាក់ដាក់ជាពលអ្នកងារ មានឲ្យត្រូវបោចស្មៅសេះស្មៅដំរីជាដើម ត្រាអស់កប្បអស់កល្បទៅ សត្វដែលកើតក្នុងវង្សនោះចុះឈ្មោះជាអ្នកងារ ជាលេខសួយទាំងអស់ទោះប៉ុន្មានៗតក៏ពុំរួចជាព្រៃងារនឹងគេឡើយសត្វណាកើតក្នុងពូជនោះ ទោះជាចេះវិជ្ជាការអ្វីៗឬមានប្រាជ្ញាយ៉ាងណាក្តី ក៏តាំងខ្លួនពុំបាន ហៅថាសត្វឥតភព្វក្នុងលោកនេះឯងៗ

ច្បាប់ដែលថាមកនេះ ជាប់ចាទម្ងន់ទៅខាងអ្នកទាបប្រាកដមួយទៀតច្បាប់នេះ បើមាននៅក្នុងប្រទេសទីណាហើយអ្នកប្រាជ្ញណា នឹងគិតគេចឲ្យរួចចេញទៅពុំបាន បើចង់រួចចេញនោះ បានតែរត់ចោលស្រុកភៀសខ្លួនទៅនៅប្រទេសទីទៃឯទៀតៗ នោះទើបបានដូចនិទានលោកតាសុខព្នងនោះឯងៗ

## រឿងភិក្ខុសុខជាព្នងគ្រូ

ឯរឿងនោះមានចៅព្នងគ្រូ១អាស្រ័យនៅក្នុងស្រុកលើរកស៊ីតាមភាសាអ្នកព្រៃ នៅយូរមកពួកព្នងដូចគ្នាកើតស្អប់ចៅនោះ វានាំគ្នាទៅប្តឹងមេកន្ត្រាញភូមិនោះ ចោទថាចៅព្នងព្រៃចេះអាបធ្មប់ធ្វើអ្នកស្រុកឲ្យស្លាប់ជាច្រើន ឯមេកន្ត្រាញ

មានអំណាចឮថា បេះអាបធ្មប់ដូច្នោះក៏ឲ្យគ្នាវាដើរកាប់សម្លាប់ព្នងដែត្រូវគេចោទនោះ ទាំងបុត្រភរិយាព្រមទាំងពូជពង្សវង្សា៧ ជួរអស់ឥតសល់ នៅតែក្មេងម្នាក់ឈ្មោះចៅសុខ ចៅនោះអាយុប្រមាណជា១០-១១ឆ្នាំ ចៅនោះនៅចាំចំការស្រូវក្នុងស្រែព្រៃ បានដឹងជាមេកន្ទ្រាញប្រើឲ្យសម្លាប់អាពុកម្តាយបងប្អូន មីងមា យាយតាអស់ដូច្នោះ ក៏ភិតភ័យមហិមា រត់ទៅឡើងចុងឈើលាក់ខ្លួនពួនអាត្មា នឹងមែកឈើស៊ុមទ្រុមសម្ងំ ឯពួកមេកន្ទ្រាញវាសម្លាប់ពូជបោះអស់ហើយ វាដឹងថា នៅសល់កូន១ ទើបវានាំគ្នាទៅរកក្មេងនោះឯចំការស្រូវដើម្បីនឹងសម្លាប់ចោលឲ្យអស់ពូជ លុះទៅដល់ចំការ វាក៏ដើរទើរកតាមជ្រោះជ្រលងគុម្ពព្រៃសព្វអន្លើក៏ពុំឃើញ ទើបវានាំគ្នាវិលមកភូមិវិញ ឯចៅក្មេងពួននៅលើចុងឈើ កាលពួកនោះទៅរកក៏បានឃើញគេកាន់ដាវកាន់កាំបិតចូលមករកខ្លួន ក៏ដឹងថាគេមកសម្លាប់អាត្មា ព្រោះក្មេងនោះដឹងច្បាប់ព្នងថាមេកន្ទ្រាញឲ្យសម្លាប់ទាំងអស់ឥតសល់ ហេតុនោះទើបចៅក្មេងខំពួនលាក់ខ្លួននឹងប្រគាបឈើ ឱបមែកឈើនោះខ្ជាប់ លុះពេលយប់ស្ងាត់ចៅក្មេងនោះចុះចាកព្រឹក្សារត់ចេញអំពីចំការ ដើរកាត់ព្រៃត្រង់ចុះ



មកភូមិក្រោម ចូលទៅសូមពួននឹងផ្ទះព្នងម្នាក់នៅដើមភូមិ ឯអ្នកផ្ទះនោះគេក៏អាណិតក្មេងនោះ ឲ្យបាយទឹកអស្រ័យហើយយកទៅលាក់ទុកក្នុងផ្ទះ ឯអាពួកមេកន្ទ្រាញដើររកក្មេងនោះពុំឃើញហើយ លុះថ្ងៃព្រឹមឡើង វាតាមរកដល់ភូមិក្រោមវាដើរស៊ើបសួររកគ្រប់ផ្ទះ ឯអ្នកស្រុកក៏ឆ្លើយប្រាប់ថាពុំឃើញទាំងអស់ ឯពួកនោះនៅសង្ស័យ ក្រែងអ្នកស្រុកលាក់បិទបាំងទុក ទើបវានាំគ្នាឡើងទើមើលគ្រប់ផ្ទះ តែផ្ទះដែលចៅក្មេងទៅពួននោះ គឺនៅខាងដើមភូមិបង្អស់ ច្បាប់ព្នងត្រូវរកមនុស្សនោះ គឺទើរកតែផ្ទះណាដែលនៅកណ្តាលគេ ឬចុងគេជាការមាំទាំងត្រង់ផ្ទះនៅដើមភូមិក៏មិនសូវមានក្តីសង្ស័យពេក តែផ្ទះដែលក្មេងពួននោះ វាពុំបានឡើងទើឲ្យមាំមួន លុះវារកពុំឃើញ ហើយទើបវានាំគ្នាវិលទៅជំរាបមេកន្ទ្រាញនោះវិញ ។

ឯអ្នកផ្ទះកាលបើពួកនោះវិលទៅអស់ហើយ ទើបនិយាយនឹងក្មេងនោះថា "បាឯងនៅនឹងយើងនេះយើងនឹងការពារពុំរួចទេ ព្រោះផ្ទះយើងនៅជិតនឹងមេកន្ទ្រាញនោះ កាលណានឹងស្ងាត់គង់នឹងដឹងដល់វាពុំខាន បើបាឯងចង់រួចជីវិត មានតែរត់ចុះ

ទៅនៅដែនខ្មែរ អើព្រឹកមិញនេះមានមេឈ្មួញរទេះខ្មែរគេ
ទៅស្រុកគេ បើដូច្នេះបាងងខំរត់ទៅតាមរទេះខ្មែរនោះឲ្យ
ទាន់ សូមដោយសារគេទៅស្រុកក្រចេះចុះ"ៗ ឯក្មេងនោះឮ
ដូច្នោះក៏ជឿតាម ទើបសំពះលាអ្នកផ្ទះហើយខំរត់តាមរទេះ
ខ្មែរ ត្រដល់ទាន់នាកណ្ដាលផ្លូវ ក៏ដើរក្រោយរទេះនោះទៅ
ដោយនឿយណាស់ពុំអាចនឹងដើរបាន ទើបឡើងជិះប្រែក
រទេះតោងក្រោយទៅៗ ឯនាយឈ្មួញបែរមកឃើញក្មេង
តោងរទេះជិះក្រោយដូច្នោះក៏ចុះមកសួរនិយាយភាសាព្នងថា
"ចៅឯងជាកូនចៅនរណា បានជាមកតោងរទេះយើងនេះ"ៗ
ឯចៅក្មេងនោះនិយាយប្រាប់ តាំងតែអំដើមដល់ចប់ឲ្យនាយ
ឈ្មួញនោះស្ដាប់នាយឈ្មួញដឹងហើយក៏កើតសេចក្ដីសង្វេគអាណិ
តពន់ពេកណាស់ ទើបថា "អើបើដូច្នោះចៅឯងទៅនៅនឹង
យើងចុះ យើងឥតកូនទេយើងយកបាងងជាកូនធម៌ កាលដែល
គេគិតបៀតបៀនបានោះយើងទទួលជាភារះ ចៅកុំជាទុក្ខ
ឡើយ" ថាហើយក៏ឲ្យក្មេងនោះជិះក្នុងរទេះ បរទៅដរាបដល់
ស្រុកក្រចេះ នាយឈ្មួញក៏បររទេះទៅផ្ទះនៃអាត្មា ដល់ហើយក៏
ឈប់នៅ តាំងនាមក្មេងនោះហៅថាសុខព្រោះចៅនោះផុតពី



សេចក្ដីទុក្ខ អំពីដែនមកន្ទ្រាញនោះហើយនាយឈ្មួញស្រឡាញ់
ចៅសុខទុកជាបុត្រនៃអាត្មា ឧស្សាហ៍បង្ហាត់បង្រៀនចៅសុខ
ឲ្យចេះនិយាយភាសាខ្មែរបាន ចៅសុខក៏ខំឧស្សាហ៍ប្រតិបត្តិបំ
រើនាយឈ្មួញនោះ ពុំឲ្យមានសេចក្ដីវង្វៀសអ្វី១ឡើយលុះនៅ
មកនាយឈ្មួញឲ្យចៅសុខទៅនៅវត្តរៀនអក្សរខ្មែរចៅសុខ
ឧស្សាហ៍រៀនសូត្រត្រទាល់តែបានសំរេចក្ដីប្រាថ្នា លុះបាន១៥
ឆ្នាំ នាយឈ្មួញឲ្យបួសជាសាមណេរហៅថានេនសុខ លុះអាយុ
បាន២១វស្សា បិតាធម៌បំបួសជាភិក្ខុ ហៅថាលោកភិក្ខុសុខនៅ
ជាសុខសប្បាយដោយលាភសក្ការ: ដែលបង្កើតមានក្នុងព្រះពុទ្ធ
សាសនានេះហោងៗ

"អើឯងស្ដាប់មើលចុះ រឿងនិទានអស់នេះគឺច្បាប់ថា អ្នក
ណាមានទោសហើយទោសនោះអាចធ្លាក់ដល់កូនដល់ចៅអ្នក
នោះ ដែលគ្នាពុំដឹងពុំឮអ្វីឡើយមែនបើច្បាប់នេះ មាននៅក្នុង
ស្រុកណាហើយលោកថាឲ្យរត់ចេញចាកស្រុកនោះឲ្យឆាប់
ទើបរក្សាជីវិតបាន ដូចលោកភិក្ខុសុខដែលសំដែងមកនេះ គួរ
ចូលចិត្តចុះ សំដែងមកក្នុងពាលវគ្គនេះ ចប់ដោយសង្ខេបតែ
ប៉ុណ្ណេះ"ៗ តពីនេះនឹងសំដែងក្នុងបណ្ឌិតវគ្គតទៅៗ

# បណ្ឌិតវគ្គ

កូនសិស្សសួរគ្រូថា រឿងមនុស្សពាលមានឧបាយកលនឹងមានអំណាចអាចបៀតបៀនយាយីមហាជនក្នុងព្រះនគរនេះ លោកគ្រូអធិប្បាយមកច្រើនរឿងច្រើនបែប ខ្ញុំករុណាបានស្តាប់ក៏ចូលចិត្តថា ពាលនេះគួរចៀសគួរវាងរាងចាលខ្លាចវាហើយ ក៏ឯមនុស្សដែលលោកបញ្ញត្តិនាម ហៅថាអ្នកប្រាជ្ញនោះ តើមានលក្ខណៈយ៉ាងណា? មានកិរិយាដូចម្តេច?។

(គ) 'ឱ្យមនុស្សដែលហៅថាអ្នកប្រាជ្ញបាននោះ"។ យើងនឹងសួរទៅឯងវិញ ក្នុងចិត្តឯងតើសំគាល់រូបលោកអ្នកណាដែលគួរហៅថា អ្នកប្រាជ្ញបាន"។

"សូមទានខ្ញុំករុណាសំគាល់ថា លោកអាចារ្យដែលចេះព្រះត្រៃបិដក១ លោកអាចារ្យដែលចេះព្រះកម្មដ្ឋាន១ លោកទាំង២ នេះហៅថាអ្នកប្រាជ្ញ?។

"អើឯងថានេះត្រូវដែរ តែមិនទាន់ចំក៏ឯលោកអ្នកចេះព្រះត្រៃបិដកព្រះកម្មដ្ឋាននោះ បើចេះហើយតែនៅមិនទាន់ទូន្មានខ្លួនឲ្យស្លូតត្រង់បាន នៅប្រកបដោយលោភៈ ទោសៈ មោហៈ ទិដ្ឋិ ខឹងឃោរជេរពោលប្រទេចផ្តាសា វាយគេកាច់



មួលព្រះពុទ្ធភាសិត ពុំប្រព្រឹត្តតាមក្រិត្យបន្ទាត់ព្រះវិន័យជាដើមយ៉ាងនេះ តើនឹងហៅថាអ្នកប្រាជ្ញបានឬដូចម្តេច"។

"ករុណា បើលោកចេះព្រះត្រៃបិដក ចេះព្រះកម្មដ្ឋានហើយចិត្តនោះនៅមានលោភៈ ទោសៈ មោហៈជាដើមយ៉ាងនេះ ក៏ពុំបានរាប់ហៅថា ជាអ្នកប្រាជ្ញឡើយ ហៅថាពាលវិញ"។

"អើដូចយ៉ាងកបិលភិក្ខុ បួសក្នុងពុទ្ធសាសនាព្រះពុទ្ធកស្សបៈជាម្ចាស់នោះ គឺជាភិក្ខុចេះព្រះត្រៃបិដកចប់ទាំងប្រាំបីហ្មឺនបួនពាន់ ធ្វើជាអាចារ្យធំ តែពុំប្រព្រឹត្តតាមធម៌តាមវិន័យ ស្រដីកាច់មួលព្រះពុទ្ធវចនៈទៅផ្សេងៗ លុះអស់អាយុទៅ ក៏ធ្លាក់ទៅសោយទុក្ខវេទនាក្នុងមហានរករងទុក្ខអស់ពុទ្ធន្តរ១ លុះដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង បានត្រាស់ក្នុងលោកនេះ នោះកបិលភិក្ខុបានរួចចាកជាតិជាសត្វនរក មកកើតជាត្រីមានពណ៌ដូចមាស តែមានមាត់នោះស្អុយ អសោចិទ្ធទៅរឿងនិទាននេះមានពិស្តារក្នុងគម្ពីរធម្មបទ ឯងស្តាប់មើលចុះ នេះលោកអាចារ្យចេះព្រះត្រៃបិដកហើយ នឹងថាអ្នកប្រាជ្ញបានឬមិនបាន" មួយទៀតខាងលោកដែលចេះព្រកម្មដ្ឋាននោះដូចយ៉ាងទេវទត្តត្ថេរ គឺបានទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានរៀនព្រះ

កម្មដ្ឋានស្ទាត់ជំនាញ ញាំងឈានលោកិយឲ្យកើតអាចសំដែងបាដិហារ្យ ដល់ក្រោយមកកើតលោភចិត្តប្រព្រឹត្តធ្វើលោហិតុប្បាទ ព្រមទាំងសង្ឃភេទកម្ម ជាកម្មយ៉ាងធំផងផែនដីមិនអាចទ្រទ្រង់ទុកបាន ក៏បើកស្រូបទំលាក់ចុះទៅសោយទុក្ខវេទនា ក្នុងមហាអវិចិនរកអស់ផែនដីនេះជាកំណត់ រឿងនេះឯងស្តាប់មើលចុះទេវទត្តនោះ ជាមនុស្សពាលឬអ្នកប្រាជ្ញ"ៗ

"ករុណាខ្ញុំស្តាប់បានហើយលោកចេះព្រះត្រៃបិដកចេះព្រះកម្មដ្ឋានចប់ក្តី តែចិត្តនៅពាលក៏ឈ្មោះថាពាលដដែល សូមទាននិមន្តលោកគ្រូម្ចាស់ សំដែងលក្ខណធម៌អ្នកប្រាជ្ញឲ្យពិស្តារបន្តិចទៅមើលទាន"ៗ "ឱលក្ខណៈអ្នកប្រាជ្ញនោះបើនិយាយដោយគតិធម៌វិញនោះ លោកចែកបុគ្គលជាពីរចំពូក គឺព្រះអរិយបុគ្គលទាំងឡាយ មានអង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាដើមនោះ ហៅថាជាអ្នកប្រាជ្ញប្រសើរវិសេសលើសលោក ចំពូក១កល្យាណបុថុជ្ជន គឺបុថុជ្ជនដែលមានគុណគឺបណ្ឌិតគប្បីរាប់នោះ ហៅថាអ្នកប្រាជ្ញប្រពៃចំពូក១ៗ

ឯអ្នកប្រាជ្ញចំណែងខាងព្រះអរិយបុគ្គលក្នុងទីនេះយើងមិនសំដែងឲ្យពិស្តារទេ ព្រោះមាននៅក្នុងចំណែកគតិធម៌នោះ



ហើយ ក្នុងប៉ែកនេះសំដែងតែពួកអ្នកប្រាជ្ញ ចំណែកខាងកល្យាណបុថុជ្ជនចំពូក១ព្រោះជាគតិលោក"ៗ

## អរិយទ្រព្យ៧ប្រការ

ស. សី. ហិ. ឱ. សុ. ចា. ប. អរិយទ្រព្យ៧ប្រការគឺសទ្ធា សេចក្តីជឿកម្ម និងផលនៃកម្មក្នុងព្រះពុទ្ធសាសនា១, សីល៥-៦-១០ ២២៨ ដ៏បរិសុទ្ធ១, អៀនខ្មាស់អំពើអាក្រក់១, សេចក្តីភ័យខ្លាចបាប១, កិរិយាត្រាប់ត្រង់នូវធម៌១, សេចក្តីបរិច្ចាគទានឬលះបង់ចោលនូវអំពើអាក្រក់១, បញ្ញាជាសម្មាទិដ្ឋិ១, ធម៌៧ប្រការនេះមាននៅលើបុថុជ្ជនណាបុថុជ្ជននោះឯងហៅថា កល្យាណបុថុជ្ជនគឺរាប់ថាជាអ្នកប្រាជ្ញបាន ៗ

## សប្បុរិសធម៌៧ ប្រការ

១-ធម្មញ្ញុតា ភាវៈជាអ្នកស្គាល់នូវហេតុនៃផលមានស្គាល់ថារបស់នេះជាហេតុជាទីតាំងនៃផលនេះៗ ជាផលដ៏បង្កើតមកអំពីហេតុនេះជាដើម ៗ

២-អត្ថញ្ញុតា ភាវៈជាអ្នកស្គាល់នូវផលនៃហេតុមានស្គាល់ថាសេចក្តីសុខនេះ ជាផលនៃហេតុនេះសេចក្តីទុក្ខនេះ ជាផលនៃហេតុនេះជាដើម ៗ

៣-អត្តញ្ញុតា ភាវៈជាអ្នកដឹងខ្លួនថាយើងមានជាតិគោត្រត្រកូលយ៉ាងនេះ សក្តិយសសម្បត្តិបរិវារប៉ុណ្ណោះ ចំណេះវិជ្ជានូវធម៌ត្រឹមប៉ុណ្ណោះៗ ហើយត្រូវប្រព្រឹត្តខ្លួនឲ្យសមគួរដល់ឋានៈដែលមាននៅយ៉ាងម្តេចៗនោះ ។

៤-មត្តញ្ញុតា ទំនងជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកចិញ្ចឹមជីវិត ដោយផ្លូវសម្មាជីវៈនិងប្រមាណក្នុងការបរិភោគល្មមសមគួរ ។

៥-កាលញ្ញុតា បែបជាអ្នកស្គាល់កាលវេលាដ៏សមគួរក្នុងពេលប្រកបកិច្ចនោះៗ ។

៦-បរិសញ្ញុតា របៀបជាអ្នកស្គាល់ប្រជុំជននិងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះៗ ថាពួកនេះកាលចូលទៅរក តោងធ្វើកិរិយាយ៉ាងនេះ ត្រូវនិយាយយ៉ាងនេះជាដើម ។

៧-បុគ្គលបរោបរញ្ញុតា សន្តានជាអ្នកស្គាល់នូវអធ្យាស្រ័យនៃបុគ្គលថា បុគ្គលនេះល្អគួរគប់ជាមិត្របុគ្គលនេះជាមនុស្សអាក្រក់ មិនគួរយកជាមិត្រជាដើម ។

សប្បុរិសធម៌ទាំង៧ នេះមាននៅលើបុគ្គលណាបុគ្គលនោះហៅថាជាអ្នកប្រាជ្ញពិតប្រាកដក្នុងលោកនេះ ។ មួយទៀត



សភាវៈធម៌ដែលនាំឲ្យប្រាសចាកក្តីចាក់ដោតគេឲ្យឈឺចាប់ផ្សេងៗ សេចក្តីមេត្តាករុណាសត្វ នាំសត្វឲ្យរួចចាកទុក្ខទោសបាន សេចក្តីបរិសុទ្ធចិត្តទៅក្នុងសត្តនិកាយ សេចក្តីទូន្មានសត្វឲ្យដើរផ្លូវល្អ គឺញុំាងពពួកសត្វឲ្យស្ថិតនៅក្នុងកុសលធម៌បាន សភាវធម៌ទាំងអស់នេះ ជារបស់នៃអ្នកប្រាជ្ញគួរចូលចិត្តចុះ ។

មួយទៀតអ្នកប្រាជ្ញនោះ បើនិយាយដោយយ៉ាងខ្លី គឺលោកស្រដីថា បុគ្គលឯណាទទួលខ្លួនឬសំគាល់ខ្លួនថាជាអ្នកល្ងង់នៅឡើយ បុគ្គលនោះឯងហៅថាជាអ្នកប្រាជ្ញវិញដូចមានបទបាលីថា៖

ពាលោ មញ្ញតិ ពាល្យំ បណ្ឌិតោ វាបិ តេន សោ
ពាលោវ បណ្ឌិតមានិ សវេ ពាលោតិ វុច្ចតិ ។

ជនឯណាដឹងខ្លួនជាពាលពិត ជននោះហៅបណ្ឌិតតាមនយោគ
ជនឯណាតាំងតួថាប្រាជ្ញព្រោក ជននោះដាក់ហៅថាជាពាលធំ ។

(ស) "សូមទានពាក្យដែលហៅថាអ្នកប្រាជ្ញៗនេះសំដៅយកបញ្ញា ដែលចេះដឹងនោះឬៗសំដៅយកចិត្តចេតសិកណាវិញ? ។

(គ) "ឱអ្នកប្រាជ្ញនោះលោកក៏រាប់យកដួងបញ្ញាចេតសិក

ដែលពិចារណាដឹងទួទៅហើយប្រព្រឹត្តទៅតាមកាលដែលគួរធ្វើបាន អ្នកប្រាជ្ញអាចដឹងហេតុពិតមិនពិតជាដើមនោះ ព្រោះលោកសំគាល់យកអាការៈដែលសំដែងចេញមកនោះ មកពិចារណាត្រិះរិះមើលឯអាការៈនោះឯង អាចសំដែងប្រាប់មកឲ្យលោកជ្រាបបានដូចនិទានព្រាហ្មណ៍ចាស់ម្នាក់មានភរិយាក្រមុំ" ។

## រឿងព្រាហ្មណ៍ចាស់មានភរិយាក្រមុំ

នាងភរិយានោះ វាសហាយនឹងព្រាហ្មណ៍មួយ ទើបវាប្រើព្រាហ្មណ៍ចាស់ជាស្វាមី ឲ្យត្រាច់ដើរទៅសូមទានគេឯស្រុកក្រៅ ព្រាហ្មណ៍ចាស់លុះអំណាចភរិយា ទើបស្ពាយបិវក្ខាចេញអំពីគ្រឹហា យាត្រាទៅស្វែងលាភតាមនិស្ស័យ ថ្ងៃ១ នោះតាព្រាហ្មណ៍ដើរទៅដល់កណ្តាលព្រៃ អស់កំឡាំងណាស់ទើបឈប់បរិភោគសត្ទូវខៅតាកកាលតាព្រាហ្មណ៍លូកយកសត្ទូវពីក្រសោប មិនបានរូតមាត់ឲ្យជិតដូចដើមវិញតាព្រាហ្មណ៍បរិភោគហើយ ក៏ចុះទៅផឹកទឹកឯត្រពាំងទឹក ។ ក្រោយនោះមានពស់វែក១ វាធំក្លិនសត្ទូវនោះវាក៏លូនចូលទៅក្នុងក្រសោបនោះឯង ឯតាព្រាហ្មណ៍ផឹកទឹកស្រេចហើយក៏ឡើងមក តាំងរូតមាត់ត្រសោបនោះខ្ជាប់ ហើយក៏ស្ពាយដើរទៅ ។



គ្រានោះមានរុក្ខទេវតា១ អង្គយល់តាព្រាហ្មណ៍ស្ពាយក្រសោបស្រោបអាសិរពិសនៅក្នុងនោះ ក៏ស្រែកប្រាប់ជាពាក្យបញ្ហាថា ហៃព្រាហ្មណ៍ជរាអើយ នែបើថ្ងៃនេះព្រាហ្មណ៍ឯងទៅមិនដល់ផ្ទះទេនោះព្រាហ្មណ៍ឯងនឹងស្លាប់កណ្តាលផ្លូវពុំខាន ថាបើថ្ងៃនេះព្រាហ្មណ៍ឯងដើរទៅដល់ផ្ទះ នោះប្រពន្ធព្រាហ្មណ៍ឯងនឹងស្លាប់ពុំខាន ឯតាព្រាហ្មណ៍កាលណាបានឮពាក្យរុក្ខទេវតានិយាយប្រាប់ជាអាថ៌បញ្ហាដូច្នោះហើយ ទើបពិចារណាគិតមិនយល់ក៏រឹងមានសេចក្តីភិតភ័យ ទោមនស្សក្រៃពេកណាស់តាំងតែសោយសោកទៅតាមផ្លូវ ដើរទៅបានដល់ក្រុងពារាណសី ចូលទៅកាន់សំណាក់បរមពោធិសត្វជាអ្នកប្រាជ្ញ ដែលជាប្រធានក្នុងព្រះនគរ ។ ពោធិសត្វបានយល់ព្រាហ្មណ៍ចាស់ យំសោកដើរចូលមកដូច្នោះក៏សួរថា "ហៃព្រាហ្មណ៍អើយ! ហេតុអ្វីក៏បានជាកើតទុក្ខ មុខជោរជលដោយទឹកភ្នែកដូច្នោះ? តាព្រាហ្មណ៍ក៏ថ្លែងចែងសេចក្តីពីដើមដល់ចប់ ជំរាបប្រាប់ពោធិសត្វសព្វប្រការ ពោធិសត្វឮដូច្នោះពិចារណាតាមពាក្យទេវតាដែលថាបើថ្ងៃនេះព្រាហ្មណ៍ទៅមិនដល់ផ្ទះ ព្រាហ្មណ៍ឯងនឹងស្លាប់កណ្តាលផ្លូវបើទៅដល់ផ្ទះនោះថាប្រពន្ធនឹងស្លាប់វិញហេតុស្លាប់នោះ

យល់ជាមានអាសិរពិស ពស់វាចូលនៅក្នុងក្រសោបនេះ គឺថាបើព្រាហ្មណ៍ទៅមិនដល់ផ្ទះគង់ព្រាហ្មណ៍ឃ្លានបាយ ហើយនឹងឈប់ស្រាយមាត់ក្រសោបយកសត្វ និមិត្តតែព្រាហ្មណ៍លូកដៃទៅ ពស់នោះនឹងចឹកដៃព្រាហ្មណ៍ៗ ក៏នឹងស្លាប់ប្រាកដ ប្រសិនបើជាព្រាហ្មណ៍ទៅដល់ផ្ទះវិញនោះព្រាហ្មណ៍គង់នឹងប្រគល់ក្រសោបនោះ ឲ្យទៅភរិយានាងភរិយានឹងស្រាយមាត់ក្រសោប នឹងយករបស់ទ្រព្យ លុះតែនាងភរិយាលូកដៃចូលទៅក្នុងក្រសោបកាលណា ពស់នោះនឹងចឹកដៃនាងភរិយាដល់នូវមរណកាលមិនខាន ។

ពោធិសត្វពិចារណាត្រិះរិះអាការៈពាក្យទេវតាយល់ហេតុមានមិនសង្ស័យ ទើបប្រើឲ្យអ្នកបំរើយកក្រសោបព្រាហ្មណ៍នោះ ទៅស្រាយមាត់នាទីវាលឯពស់វែកនោះ និមិត្តតែមាត់ក្រសោបនោះរសាយហើយ ទើបវាលូនចូលមកមួយរំពេច ។

បណ្តាមហាជននឹងព្រាហ្មណ៍ចាស់នោះបានឃើញពស់វែកចេញចាកក្រសោបដូច្នោះហើយនាំគ្នាឲ្យសព្វសាធុការសរសើរប្រាជ្ញាបារមីនៃពោធិសត្វ ជាអនេកបរិយាយផ្សេងៗ ពោធិសត្វក៏ឲ្យអ្នកបំរើចាប់ពស់នោះយកទៅលែងទីព្រៃ ហើយ



ប្រាប់ព្រាហ្មណ៍ថា "តាឯងចូរមើលសេចក្តីអន្តរាយជីវិតតាឯងដោយពស់វែកនេះចុះ" ។ ព្រាហ្មណ៍ចាស់សំពះពោធិសត្វសរសើរថា "ខ្ញុំបាទបានរួចជីវិតក្នុងគ្រានេះ ក៏ព្រោះមកបានជួបនឹងលោកជាអ្នកប្រាជ្ញអាចរកសេចក្តីសុខបាន ខ្ញុំបាទពុំមានវត្ថុអ្វីជាឧត្តមសមគួរ នឹងបូជាតបគុណឡើយមានតែប្រមាមដៃទាំង ១០ ខ្ញុំវន្ទាតបគុណលោកក្នុងគ្រានេះ" ។

ពោធិសត្វសួរថា "ព្រាហ្មណ៍ឯងចាស់ជរាហើយនរណាប្រើតាឯងឲ្យសូមទានគេដូច្នោះ" ។

ព្រាហ្មណ៍ជំរាបថា "ប្រពន្ធខ្ញុំបាទប្រើមក" ។ នាង "ប្រពន្ធតាឯងនោះតើជា ស្រីចាស់ឬជាក្រមុំ?" ។

"សូមទាននៅក្រមុំក្មេង" ។

ពោធិសត្វពិចារណាអាការនោះទៀត ក៏យល់ថានាងនោះមានសហាយប្រាកដ ទើបថា "អើព្រាហ្មណ៍, នាងប្រពន្ធតាឯងនោះ មិនសុចរិតនឹងតាឯងទេ បើតាឯងទៅដល់ផ្ទះ ហើយចូលទៅក្នុងវេលារាត្រីស្ងាត់របស់ទ្រព្យ ដែលតាឯងបាននេះ ចូរតាយកទៅឲ្យឃើញទាំងអស់គួរណាស់ទុកខ្លះ" ពោធិសត្វប្រដៅព្រាហ្មណ៍នោះស្រេចហើយ ក៏ឲ្យដំណើរព្រាហ្មណ៍នោះទៅកាន់

ស្រុកៗ តាព្រាហ្មណ៍ក៏លាពោធិសត្វដើរទៅកាន់ផ្ទះអាត្មាដល់ទៅក៏ជួនវេលារាត្រីស្ងាត់ៗ

ឯមេព្រាហ្មណីជាប្រពន្ធនោះតាំងតែពីប្ដីចេញទៅស្វែងរកលាភបាត់ វាក៏តែងនាំចៅព្រាហ្មណ៍កំឡោះសហាយនោះមកដេកជាប្រក្រតីៗ

តាព្រាហ្មណ៍ទៅដល់ផ្ទះក៏យកប្រាក់ទៅលាក់នៅខាងជើងសសរផ្ទះ ហើយទើបហៅប្រពន្ធឲ្យបើកទ្វារផ្ទះទទួលខ្លួនៗ ឯមេនោះឮសូរប្ដីមកដល់ក៏ភិតភ័យ ទើបបណ្ដោះសហាយឲ្យចុះទៅតាមបង្អួច ហើយវាធ្វើជាមាយាបើទ្វារម្នីម្នាទទួលព្រាហ្មណ៍ឲ្យឡើងទៅ តាព្រាហ្មណ៍ឡើងដល់ផ្ទះហើយក៏និយាយចរចាប្រស្រ័យសុខទុក្ខតាមធម្មតាៗ នាងភរិយាក៏សំណេះសំណាលសួរអំពីលាភដែលទៅស្វែងនោះរឿយៗៗ ព្រាហ្មណ៍លុះអំណាចភរិយាក្រមុំ ក៏ពុំអាចបិទបាំងប្រាក់ដែលខ្លួនកប់ទុកនោះឡើយ ឆ្លើយប្រាប់ថា ខ្លួនបានប្រាក់មកកប់លាក់នៅជើងសសរផ្ទះៗ

ឯសហាយ កាលវាចុះពីផ្ទះទៅនោះវាពុំរត់ទៅឯណាឡើយ វាលបនៅក្រោមផ្ទះចាំស្ដាប់ព្រាហ្មណ៍ប្ដីនឹងប្រពន្ធនិយាយអ្វីៗ លុះវាឮថាប្រាក់១០០កហាបណៈ ព្រាហ្មណ៍កប់លាក់នៅខាងជើង



សសរផ្ទះដូច្នោះ វាក៏ទៅកកាយយកបានវាក៏លួចយកទៅផ្ទះវាហោងៗ

ព្រាហ្មណ៍ចាស់នឹងភរិយាក៏ដេកនៅតាមបវេណីលុះព្រឹកឡើងព្រាហ្មណ៍ភ្ញាក់ចាកដំណេក ដើរទៅមើលប្រាក់ដែលខ្លួនកប់លាក់នោះ ក៏ពុំឃើញប្រាក់នោះ ព្រាហ្មណ៍កើតទុក្ខមហិមាគិតថា "សេចក្ដីអន្ដរាយអញដល់មកទៀតហើយ បើដូច្នេះមានតែទៅរកលោកអ្នកប្រាជ្ញនោះ ឲ្យលោកជួយរកប្រាក់ដែលអានោះលួចយកទៅនោះទើបបាន" គិតហើយតាព្រាហ្មណ៍ក៏រៀបអាត្មា ដើរទៅកាន់សំណាក់បរមពោធិសត្វឯក្រុងពារាណសីដល់ហើយក៏ជំរាបសេចក្ដីតាំងអំពីដើមដល់ចប់សព្វប្រការៗ

ឯពោធិសត្វ បានស្ដាប់ព្រាហ្មណ៍ថ្លែងសេចក្ដីដូច្នោះហើយ ទើបរិះគិតអាការចោរលួចប្រាក់នោះក៏យល់ដោយប្រាជ្ញមួយរំពេច ទើបប្រាប់ព្រាហ្មណ៍ថា "តាឯងវិលទៅផ្ទះវិញប្រាប់ប្រពន្ធតាឯងថា ខ្លួនតាឯងបានបន់ទេវតាថា បើខ្លួនបានមកដល់ស្រុកសុខសប្បាយកាលណា នឹងធ្វើបុណ្យគឺនិមន្តព្រាហ្មណ៍ប្រាំមួយនាក់មកឆាន់ ចំណែកខាងតាឯង៣ នាក់ចំណែកខាងប្រពន្ធ៣នាក់ ឆាន់៣ ថ្ងៃតែឲ្យផ្លាស់រូបព្រាហ្មណ៍ដែលឆាន់នោះកុំឲ្យ

យកដដែលក្នុងថ្ងៃដើម៦ រូប ថ្ងៃទី៣ ឲ្យផ្លាស់និមន្តព្រាហ្មណ៍៦ រូបទៀតមកឆាន់ ថ្ងៃទី៣ ឲ្យផ្លាស់និមន្តព្រាហ្មណ៍ឯទៀត ៦ រូបទៀតមកឆាន់ហើយតាឯងចាំមើលព្រាហ្មណ៍ខាងប្រពន្ធនោះ ជាវាផ្លាស់រូបទាំង៣ ឬៗយ៉ាងណានោះបើព្រាហ្មណ៍ណាជាសង្សារវាៗ នឹងនិមន្តមកឆាន់ដដែលមិនផ្លាស់ទេ បើរូបណានៅឆាន់ទាំង៣ ថ្ងៃរូបនោះហើយជាសហាយរបស់វា ចូរតាឯងកំណត់ទុកក្នុងចិត្ត ហើយមកប្រាប់យើងជាឆាប់យើងនឹងទៅចាប់តួអាចោរលួចប្រាក់នោះឯង' ៗ ពោធិសត្វប្រាប់ឧបាយសព្វប្រការហើយ ក៏ឲ្យព្រាហ្មណ៍ចាស់នោះវិលទៅទីលំនៅវិញ ៗ ព្រាហ្មណ៍ក៏លាពោធិសត្វទៅផ្ទះវិញ ដល់ហើយក៏ថ្លែងសេចក្តីនោះប្រាប់នាងភរិយ តាមពាក្យនៃពោធិសត្វសព្វប្រការ ៗ ឯនាងភរិយាក៏ធ្វើតាម គឺចាត់ចែងភោជនាហារស្រេចហើយ ក៏និមន្តព្រាហ្មណ៍កំឡោះ ជាសហាយនោះមកឆាន់ទាំង៣ ថ្ងៃតែរូបព្រាហ្មណ៍ឯទៀតៗនោះផ្លាស់តាមបង្គាប់ព្រាហ្មណ៍នោះឯង ៗ ឯព្រាហ្មណ៍ចាស់ កាលណាបើឃើញព្រាហ្មណ៍កំឡោះខាងប្រពន្ធមកឆាន់ទាំង៣ ថ្ងៃដូច្នោះ ក៏កំណត់កត់ចាំរូបចាំឈ្មោះ ហើយយកសេចក្តីនោះទៅជំរាបដល់បរមពោធិសត្វ ៗ ក៏ប្រើឲ្យអ្នក



បំរើទៅចាប់យកព្រាហ្មណ៍កំឡោះនោះមក គំរាមសួរតាមហេតុពិរុទ្ធព្រាហ្មណ៍កំឡោះពុំអាចប្រកែកគេចបាន ក៏ទទួលសារភាពជាចោរមែន ទើបទៅយកប្រាក់ដែលខ្លួនលួចនោះ មកប្រគល់ឲ្យព្រាហ្មណ៍ចាស់វិញ សូមទោសនឹងបរមពោធិសត្វៗ ក៏តិះដៀលជាអនេកបរិយាយ ហើយទូន្មានឲ្យលះបង់ចោលនូវអំពើពុតពាលហើយលែងឲ្យវិលទៅស្រុកវិញ ៗ ព្រាហ្មណ៍បានប្រាក់វិញក៏សរសើរប្រាជ្ញានៃពោធិសត្វ ហើយតម្កល់នូវបរមពោធិសត្វ ជាគ្រូអាចារ្យចាប់ដើមពីថ្ងៃនោះមក ៗ

រឿងរ៉ាវនេះមានសេចក្តីពិស្តារក្នុងព្រះគម្ពីរ យើងទាញយកមកសំដែងនេះតែជាន័យសង្ខេប ជាបែបឲ្យឃើញថាលោកអ្នកមានប្រាជ្ញាពិចារណាតាមអាការៈដែលចេញមកនោះពិចារណាដេញរកហេតុរកបច្ច័យ ទាល់តែការនោះច្បាស់ឡើងប្រាកដដូចសំដែងមកនោះ ៗ

មួយទៀត រឿងអ្នកប្រាជ្ញពីបុរាណដែលមានមកក្នុងគម្ពីរបាលីដោយពិតនោះ យ៉ាងដូចអង្គព្រះមហោសថបរមពោធិសត្វក្តី ឯងគប្បីដឹងថាជាអ្នកប្រាជ្ញប្រសើរវិសេសចុះ ៗ

មែនពិត ឯអ្នកមានប្រាជ្ញាឆ្លាសវាងវៃនោះ មិនភ្លើភាន់សតិ

ទៅផ្កាស អាចគេចកែខ្លួនបានក្នុងប្រជុំជនឬការដែលមានដល់មកមួយរំពេច ដូចនិទានមាន់ចែកែខ្លួនផុតអំពីសត្វសំពោចបាន ៗ

## រឿងសត្វសំពោចនឹងមាន់ចែ

មានសត្វសំពោច១ ដើរទៅឃើញមាន់ចែទំនៅលើប្រគាបឈើ ហើយសំពោចណើចង់ស៊ីមាន់ទើបនិយាយជាកលឧបាយមុសាវាទថា "ចែនមាន់ចែជាសំឡាញ់អើយ! អើឥឡូវអញកាន់ព្រះអាជ្ញា ព្រះមហិសសុរាធិបតី ទ្រង់ត្រាស់ប្រើឲ្យប្រកាសប្រាប់អស់បណ្តាពួកសត្វដែលជាពៀរសត្រូវ នឹងគ្នានោះថាឲ្យព្រមព្រៀងជានឹងគ្នា ចាប់ដើមពីថ្ងៃនេះទៅកុំឲ្យមានសត្វណាឃាឃីគ្នាឡើយ ចែនមាន់ចែយើងបានសុខសប្បាយហើយ ព្រោះព្រះជាម្ចាស់លោកប្រាសតាំងច្បាស់ថ្មីថា ឲ្យយើងជានឹងគ្នាឥឡូវនេះ ខ្ញុំយល់ថា បាឯងក៏មកជាសំឡាញ់ដូចចង់ប្អូនគ្នាពិតៗ ចូរឯងចុះមកឲ្យគ្នាឱបថើបជាការមេត្រីបន្តិចទៅអេះ"ៗ

ឯមាន់ចែមានប្រាជ្ញាវាងវៃក៏តបភ្លាមទៅថា "អើបងសំពោចបងឯងកាន់ព្រះរាជអាជ្ញាព្រះជាម្ចាស់មកបង្គាប់ថា ឲ្យយើងជានឹងគ្នានេះ ជាការល្អវិសេសណាស់ហើយបង ខ្ញុំឃើញបងឯង



ហើយក៏មានចិត្តស្រឡាញ់ចង់ចុះទៅទទួលសេចក្តីស្និទ្ធស្នាលស្នេហានឹងអ្នកបងដែរ តែការនេះឈប់សិនចុះ ព្រោះទីនេះមានឆ្កែមួយវានៅជាមួយនឹងខ្ញុំនេះ ឥឡូវវាទៅរកស៊ីក្រៅបាត់ពុំទាន់មកដល់នៅឡើយ យើងចាំជុំគ្នាទាំង៣ ប្រាណ ហើយសឹមយើងជួបគ្នានឹងបានក្រសោបឱបគ្នា ជាការមេត្រីយ៉ាងធំតែម្តង" លុះមាន់ចែនិយាយដូច្នោះហើយ ធ្វើជាបែរមើលទៅទិសខាងជើងហើយស្រែកថា "បងឆ្កែមកហើយ អើបងសុនខអញ្ជើញបោលចូលមកឲ្យឆាប់ ត្បិតបងសំពោចគេមកនៅរង់ចាំបងឯង"ៗ ឯសំពោចឮថា ឆ្កែមកដូច្នោះហើយក៏ភិតភ័យ ព្រោះខ្លួននឹងឆ្កែជាសត្រូវនឹងគ្នាទើបម្នីម្នារត់ចេញអំពីទីនោះចូលព្រៃទៅៗ មាន់ចែក៏រឹងតែបង្អៅថា "បងសុនខចូរមកឲ្យឆាប់ៗបងសំពោចកុំអាលទៅណាឈប់សិន បងសុនខគេមកដល់ហើយ"ៗ ឯសំពោចក៏ឆ្លើយថា "អាជ្ញាក្តៅណាស់នៅមិនបានទេ" ថាហើយក៏រត់ចូលព្រៃទៅៗ

រឿងនេះឯងស្តាប់មើលចុះ មាន់ចែមានប្រាជ្ញស្គាល់អាការសំពោចកុហកមុសាវាទហើយ គឺស្គាល់អាការៈកុហកបានមួយរំពេចពាក្យមាន់ចែស្រែកឡូកឲ្យសំពោចថា "អាចោលម្សៀត

ចេះមកពោលពាក្យថា ឯងកាន់ព្រះរាជាមកប្រកាសថាឲ្យសត្វ
ដែលវាសីកសត្រូវនឹងគ្នានោះ ត្រូវឲ្យជានឹងគ្នាតែអញនឹងឯង
ឯត្រង់ឆ្កែនឹងឯងត្រឡប់ជាមិនសាមគ្គីវិញ អាណាជឿឯងបាន
ពាក្យមិនសាធារណៈទូទៅយ៉ាងនេះ ។

**(និទាននេះមានដំណាលក្នុងក្បួនបារាំងសែស)**

## រឿងសត្វឥន្ទ្រីរបស់ព្រះឥសូរ

មានសត្វឥន្ទ្រី១ ជាទីគាប់ព្រះទ័យនៃព្រះឥសូរៗ ស្រឡាញ់
រាប់អានជាទីទុកព្រះទ័យ ឯសត្វឥន្ទ្រីនោះបើចង់បានអ្វីៗក្ដីឬ
វាចង់ស៊ីសាច់សត្វណាក្ដី វាទូលព្រះឥសូរថា វាយល់សុបិនត្រូវស៊ី
សត្វនេះឯព្រះឥសូរក៏ចេះជឿតាម ហៅសត្វនោះមកឲ្យវាស៊ី
តែរឿយៗ ក៏បណ្ដាសត្វទាំងឡាយមានគោ ក្របីជាដើម កើត
ក្ដៅក្រហាយនឹងសត្វឥន្ទ្រីនោះមហិមា តែពុំហ៊ានថាអ្វី ព្រោះ
ខ្លាចអំណាចព្រះឥសូរជាម្ចាស់លើសសត្វក្នុងលោកនេះ ។

ថ្ងៃ១ សត្វឥន្ទ្រីនោះវាចង់ស៊ីសាច់ស្ដេចដំរីស ទើបវាទូលព្រះ
ឥសូរថា វាយល់សុបិនត្រូវស៊ីសាច់ស្ដេចដំរីស ឯព្រះឥសូរក៏ជឿ
តាម ទើបឲ្យបំរើទៅប្រាប់ដំរីសម្ដាយនឹងកូនថា ឲ្យទៅលាង
ខ្លួនឲ្យស្អាតហើយឲ្យចូលមកក្នុងវេលាព្រឹកនេះ ឲ្យសត្វឥន្ទ្រី



គេស៊ី ត្បិតគេយល់សុបិនត្រូវត្រង់រូបខ្លួនហើយ ឯដំរីសម្ដាយ
នឹងកូនកាលណាបើឮថា ព្រះឥសូរឲ្យហៅខ្លួនទៅ ឲ្យសត្វឥន្ទ្រី
ស៊ីដូច្នោះហើយ ក៏ភិតភ័យនឹងសេចក្ដីស្លាប់នោះមហិមា នាំគ្នា
សោករិយោកទៅផ្សេងៗ ពុំដឹងបើនឹងរកលោកអ្នកឯណាមេ
ត្តាជួយកែដោះជីវិតនៃអាត្មាបាន ហើយក៏នាំគ្នាដើរចុះទៅក្នុង
ស្រះ ដើម្បីនឹងងូតទឹកដុសលាងកាយ ។

គ្រាកាលនោះ មានសត្វទីទុយមួយទំនៅលើមែកឈើ បាន
ឃើញដំរីម្ដាយនឹងកូនដើរយំសោកដូច្នោះហើយ ក៏សួរទៅថា
"នែដំរីសអ្នកមានទុក្ខទោមនស្សព្រោះហេតុអ្វី? ឯដំរីសម្ដាយ
នឹងកូនក៏ថ្លែងសេចក្ដីទុក្ខនោះប្រាប់ទីទុយ តាំងអំពីដើមដល់ចប់
សព្វប្រការ ។ ឯទីទុយឮដូច្នោះហើយក៏ថា "ឱព្រះឥសូរ លោក
ម្ដេចក៏ប្រកបទៅដោយឆន្ទាគតិគឺលំអៀងច្បាប់ លំអៀង
សេចក្ដីទៅតាមសេចក្ដីស្រឡាញ់ ទៅជឿស្ដាប់តែពាក្យសត្វ
ឥន្ទ្រីឲ្យឃាឃីគេឯទៀតដូច្នោះ" ។ ដំរីសក៏ព្រមតាម ហើយឲ្យ
ទីទុយជិះទំលើក្បាលកូនដំរីស ចរទៅកាន់សំណាកព្រះឥសូរឮ
ដ៏ភ្នំកៃលាសមហាស្ថាន ដល់ហើយទីទុយក៏ចុះបាកក្បាលនៃដំរីស
ចូលទៅទំទៀបបល្លង្កទីនាងព្រះឥសូរហើយទូលថា "បពិត្រ

ព្រះអង្គជាកំពូលលើសលោក ព្រះអង្គមានការអ្វីបានជាទ្រង់ឲ្យហៅដំរីសជាបាវខ្ញុំទូលព្រះបង្គំមកនេះ មានហេតុភេទយ៉ាងណាព្រះករុណា"។ ព្រះឥសូរ៍ក៏ឆ្លើយថា "អើទីទុយបាវឯងនេះ ត្រូវដល់សេចក្ដីស្លាប់ហើយក្នុងថ្ងៃនេះត្បិតសត្វឥន្ទ្រីយល់សុបិនថាត្រូវបរិភោគសាច់ដំរីស ហេតុនោះទើបយើងឲ្យហៅដំរីសជាបាវឯងមកឲ្យគេស៊ី"។

ទីទុយតមថា "សូមទានឯកិរិយាយល់សុបិនរបស់សត្វឥន្ទ្រីនោះ ជាទៀងពិតប្រាកដព្រះអង្គយកជាប្រមាណណាស់ទៅឬយ៉ាងម្ដេច?។

"អើទីទុយ សត្វឥន្ទ្រីនោះគេយល់សុបិនហើយសុបិននោះមិត្ត ទៀងពិតណាស់ យើងយកជាប្រមាណបាន"។ "ក្រាបទូលខ្ញុំទូលព្រះបង្គំ ក៏ជឿតាមព្រះបន្ទូល ដែលទ្រង់ជឿសុបិនសត្វឥន្ទ្រីនោះ ដំរីសបាវខ្ញុំព្រះករុណាវិសេសក៏គួរដល់ស្លាប់ហើយ ខ្ញុំម្ចាស់នាំមកថ្វាយ ឲ្យទ្រង់ប្រទានដំរីសឲ្យសត្វឥន្ទ្រីគេបរិភោគចុះ តែខ្ញុំល្អងធូលីព្រះបាទយប់មិញនេះ មានធុរៈដើរចាប់ក្ដាមបរិភោគ ពុំបានទទួលទានដំណេកបានមួយស្រឡេតសិន ហើយខ្ញុំនាបាវទៅឲ្យសត្វឥន្ទ្រីនោះគេស៊ី" ថាហើយទីទុយក៏ធ្វើជាធ្មេច



តែភ្នែកសម្ងំដេកបន្ដិច ទីទុយក៏ធ្វើជាភ្ញាក់ឡើងហើយពត់ខ្លួនពត់ប្រាណសសិតស្លាប ធ្វើកិរិយារីករាយហើយទូលព្រះឥសូរថា "សូមទ្រង់ព្រះមេត្តាប្រោសខ្ញុំម្ចាស់ទទួលទានដំណេកអំបាញ់មិញនេះទៅ យល់សុបិនល្អណាស់ ជាសុបិនមង្គលហៅសុភនិមិត្ត។ ព្រះឥសូរក៏សួរថា "បាឯងយល់សុបិននោះដូចម្ដេច ចូរនិយាយទៅមើល? ទីទុយក៏ទូលថា "សុបិនខ្ញុំម្ចាស់នេះសេចក្ដីប្លែកណាស់ ទៅជាមិនហ៊ាននិយាយផង"។ "អើឯងនិយាយទៅមើលសុបិនឯងនោះយ៉ាងណា?។ "សូមទាន សុបិននោះឃើញថាសម្ដេចព្រះនាងឱមាភោគវតី ជាព្រះរាជមហេសីល្អងធូលីព្រះបាទក៏ប្រោសប្រទានឲ្យមកជាភរិយាខ្ញុំ សុបិនខ្ញុំនេះទៀងពិតប្រាកដណាស់ យកជាប្រមាណបានបើដូច្នេះសូមល្អងធូលីព្រះបាទ ហើយព្រះនាងឱមាភោគវតីនោះមក ព្រះរាជទានឲ្យខ្ញុំទុកជាព្រះកេរ្ដ៍របស់ព្រះករុណាវិសេស"។ ព្រះឥសូរឮដូច្នោះក៏តូចព្រះរាជហឫទ័យ ទើបត្រាស់ថា "អាឯងយល់សុបិននេះតែផ្ដាសទេ យើងនឹងយកជាប្រមាណពុំបាន នឹងជឿស្ដាប់ពុំបានទេអាទីទុយអើយ"។ ទីទុយតបថា "ក្ដីយល់សុបិនខាងទូលព្រះបង្គំព្រះអង្គថាយកជាប្រមាណពុំបាន ចុះខាងសត្វឥន្ទ្រីនោះ ម្ដេចក៏

ព្រះអង្គជឿស្ដាប់យកជាប្រមាណបាន? អើបើសុបិនខ្ញុំមិនពិត សុបិនសត្វឥន្ទ្រីនោះក៏មិនពិតដូចគ្នា វិស័យសត្វសកុណជាតិដូចគ្នា សូមព្រះអង្គកាត់សេចក្ដីនេះឲ្យបានប្រកបដោយយុត្តិធម៌ទាំងសងខាងឲ្យទាន ៗ ព្រះឥស្សូរឮទីទុយស្ដីដូច្នោះហើយក៏ទាញ់ទាល់ព្រះហឫទ័យណាស់ ទើបត្រាស់ថា "អើបើដូច្នោះ ចូរឯងនាំយកដំរីសជាបាវឯង វិលទៅកាន់ទីលំនៅឯងវិញចុះ ការនេះយើងលើកលែងគ្នាតែប៉ុណ្ណោះ" ៗ

ទីទុយក៏ក្រាបថ្វាយបង្គំលា នាំដំរីសទៅទីលំនៅបានជួបគ្នាម្ដាយនឹងកូន នៅជាសុខសប្បាយរួចអំពីអន្តរាយជីវិត ព្រោះបានសេពគប់ទៅលើមិត្ត គឺទីទុយជាអ្នកប្រាជ្ញ អាចដោះទុក្ខបានដោយប្រការយ៉ាងនេះ ៗ

រឿងនិទាននេះឯងស្ដាប់មើលចុះការអ្នកមានបញ្ញានោះ ហៅថា អ្នកប្រាជ្ញបានក្នុងលោកយើងនេះ ៗ

ទីអើយទីទុយ រូបរាងទុយមុយ អាក្រក់តែកាយ តែត្រង់បញ្ញាជ្រះថ្លាពណ្ណរាយ អាចកែដោះស្រាយ តព្រះឥស្សូរ ៗ ឥស្សូរភូមិន្ទកាន់ខាងសុបិន ឥន្ទ្រីបក្សី វាក្លែងតម្រូវ ថាត្រូវដំរី ធ្លាក់ជាចំណីនៃវាភោក្ដា ៗ ទីទុយបញ្ចប់ យកសប្ដិនឹងសប្ដិ លើកឡើងតវ៉ា



ទារយកមហេសី គឺនាងឱមា ផ្ចាញ់ព្រះប្រាជ្ញា មហិស្សរាចេញហោង ៗ

## តម្រាលោកិយស្ដីស្មើគ្នា

## រឿងក្មេងកំព្រានឹងព្រះចៅផែនដី

មានកូនក្មេង១ នាក់អាយុ១៥ ឆ្នាំជាក្មេងកំព្រាឥតមានមាតាបិតារក្សា ក្មេងនោះទៅនៅដោយសាររោងនាយពិសេស គឺរោងគ្រួសំរាប់ធ្វើក្រយាស្ងោយអ្នកស្ដេច ឯនាយពិសេសគេក៏អាណិតមេត្តាឲ្យនៅហើយគេប្រើឲ្យលាងចាន លាងថាស ជូតសមស្លាបព្រាឲ្យប្រាក់ខែក្នុងមួយខែជាប្រាក់ ៥៦ កាក់លម្មការសោហ៊ុយបាន ក្មេងនោះឧស្សាហ៍ធ្វើក្នុងមុខក្រសួងរបស់ខ្លួនបានប្រាក់តែរាល់ខែរៀងមក ៗ ឯព្រះបរមខត្តិយាព្រះចៅផែនដី ស្ដេចតែងយាងមកទតការក្នុងរោងពិសេស បានទ្រង់យល់ក្មេងនោះ ធ្វើការស៊ីឈ្នួលលាងចាននោះរឿយៗ ៗ ថ្ងៃ១ ស្ដេចទ្រង់យាងមករោងពិសេស យល់កូនក្មេងកំពុងតែលាងចាននៅក្រៅរោង ស្ដេចត្រាស់សួរថា "ចៅឯងស៊ីឈ្នួលលាងចានសព្វថ្ងៃនេះមានប្រាក់ប៉ុន្មានហើយ" ៗ ក្មេងនោះឆ្លើយថា "សព្វថ្ងៃនេះខ្ញុំមានស្មើគ្នានឹងស្ដេចផែនដី" ៗ ស្ដេចត្រាស់ថា "ការដែល

វកស៊ីឈ្នួលគេក្នុងលោកនេះ គឺការស៊ីឈ្នួលលាងចាន មានសម្បត្តិស្មើនឹងយើងជាម្ចាស់ផែនដីផ្ទៃក្រោមនេះ"ៗ ក្មេងនេះក៏អធិប្បាយថា "ខ្ញុំស៊ីឈ្នួលគេសព្វថ្ងៃនេះ ក្នុង១ ខែគេឲ្យ ៥ ៦ កាក់ក៏ពិតមែន តែការដែលទទួលទានបាយក៏ត្រឹម១ ឆ្អែតទទួលទានដំណេកក៏ត្រឹម១ ពេល ឯអ្នកស្ដេចដែលមានសម្បត្តិច្រើនរាប់មិនអស់នោះសោត ក្នុង១ ថ្ងៃក៏គង់សោយព្រះក្រយាស្ងោយត្រឹមតែ១ ឆ្អែតដូចគ្នានឹងសោយឲ្យលើសអំពីនោះទៅក៏ទេ នឹងការដែលទ្រង់ផ្ទំសោតក៏ទ្រង់ផ្ទំត្រឹម១ ពេលដូចគ្នា នឹងឲ្យលើសលែងពីនោះទៅក៏ទេ ហេតុនោះទើបខ្ញុំថាខ្លួនខ្ញុំមានសម្បត្តិស្មើនឹងម្ចាស់ផែនដីដែរ"ៗ ឯមហាក្សត្រាធិបតីបាន ស្ដាប់ពាក្យក្មេង វាអធិប្បាយប្រាប់ហេតុយក១ ឆ្អែតជាប្រមាណដូច្នោះហើយ ក៏ទ្រង់យល់ថាពិតថាមែនប្រាកដណាស់ ទ្រង់ពិចារណាមើលហេតុទៅក៏ពុំមានខុសអំពីគ្នា គឺអ្នកក្រក៏ស៊ីត្រឹម១ ឆ្អែតអ្នកមានក៏ស៊ីត្រឹម១ ឆ្អែតដូចគ្នា ស្ដេចមានព្រះហឫទ័យស្រឡាញ់ពាក្យក្មេងនោះក្រៃពេក ទើបទ្រង់ប្រទានមានប្រាក់សម្ពត់ខោអាវឲ្យទៅក្មេងនោះ ហើយទ្រង់ចារឹកពាក្យក្មេងនោះហៅថា ពាក្យអ្នកប្រាជ្ញបានក្នុងលោកនេះៗ



## មានរឿង ១ ទៀត

## ឈ្មោះជាតម្រាស្របតបតគ្នា

### រឿងព្រះចៅផែនដីនឹងក្មេងឃ្វាលក្របី

មានមហាក្សត្រាធិបតី១ ព្រះអង្គ ស្ដេចនាំពួកសេវកាមាត្យមុខមន្ត្រីទាំងឡាយ សឹងនាំគ្នារៀបក្បួនហែស្ដេចទៅតាមមុខងារ លុះទៅដល់ទីទួល១ ជាទីសមគួរដាក់ឈប់អាស្រ័យបរិភោគភោជនាហារ នាវេលាព្រឹក ទើបស្ដេចឲ្យពួកអ្នកពិសេសដាំស្លចំអិនក្រយាស្ងោយរង់ចាំនៅ ឯព្រះអង្គឯងនឹងពួកទាហានសេះ ក៏បរសេះចេញទៅដេញសត្វ បាញ់សត្វម្រឹគម្រឹគាតាមផ្លូវព្រៃ ឯពួកមន្ត្រីក៏នាំគ្នាជិះសេះបរតាមស្ដេចទៅ ឯសេះស្ដេចនោះលឿនលើសសេះពួកមន្ត្រី ទើបបរទៅដាច់អស់សេះទាំងពួង ពួកមន្ត្រីតាមពុំទាន់ ស្ដេចបរព្រះទីនាំងចូលព្រៃចេញវាលវង្វេងផ្លូវទៅតែ១ ព្រះអង្គឯង លុះពេលថ្ងៃត្រង់ស្ដេចរកផ្លូវនឹងវិលមកទីជម្រំដែលចតនោះពុំឃើញ កើតឃ្លានព្រះស្ងោយពន់ពេក ស្ដេចខំបរសេះព្រះទីនាំងកាត់ព្រៃធំចេញទៅដល់ទីមាត់បឹង១ បានឮសព្ទត្រដោកគោក្របី នឹងសំឡេងក្មេងឃ្វាលក្របីវានិយាយគ្នា ទើបទ្រង់បរសេះកាត់តម្រង់

ទៅទីនោះលុះដល់បានឃើញក្មេងគង្វាលគោក្របីម្នាក់ ទើបត្រាស់សួរក្មេងនោះថា អើអានាង ទីទួលគោកចែងកន្លែងគេតែងមកឈប់កាក់ដាក់អាស្រ័យនោះ ចៅឯងបានដឹងបានស្គាល់ខ្លះឬទេ ៗ

ឯក្មេងពុំស្គាល់ជាស្ដេច នឹកស្មានជាមនុស្សដទៃផ្ដាសទើបនិយាយប្រាប់ថា "ទីទួលគោកចែងនោះខ្ញុំបាទស្គាល់ច្បាស់ណាស់ ទៅពីនេះទៅមិនឆ្ងាយប៉ុន្មានទេ ចូរអ្នកបរសេះទៅខាងទិសឧត្តរនោះចុះ ថាហើយក្មេងនោះលើកដៃចង្អុលប្រាប់ផ្លូវ ៗ ឯមហាក្សត្រាធិបតី ស្ដេចនឹងទៅតែឯងក្រែងវង្វេងផ្លូវទៀត ប្រះហឫទ័យចង់បានក្មេងនោះ ជូនទៅជាមួយផងទើបត្រាស់ថា "អានាងឯងជិះសេះខាងក្រោយ យើងជូនយើងទៅឲ្យដល់ទីទួលគោកចែងនោះ សូមឯងវិលមកវិញ យើងនឹងឲ្យប្រាក់ឯងជារង្វាន់ថ្លៃជូនគ្នានោះ" ៗ

ក្មេងនោះក៏ព្រមជូនផ្លូវ ទើបវាឡើងជិះសេះខាងក្រោយឲ្យស្ដេចបរចរទៅតាមមាគ៌ា ខ្លួនវាជាមគ្គុទ្ទេសក៍ចង្អុលផ្លូវបរទៅតាមលំដាប់វាលព្រៃ ៗ លុះដល់កណ្ដាលផ្លូវស្ដេចទ្រង់ត្រាស់ថា "អើអានាងឯងនៅស្រុកក្រៅនេះ ឯងបានស្គាល់ស្ដេចជាម្ចាស់



ផែនដីឬទេ? "បាទទេខ្ញុំបាទមិនដែលស្គាល់ទេបង មិនដែលឃើញសោះ អ្នកស្ដេចនោះឮតែម៉ែឪប្រាប់ថាហ្លួង ហ្លួងនោះពុំដឹងជាមុខមាត់យ៉ាងណាទេ" ៗ "ឱឯងចង់យល់ចង់ស្គាល់ហ្លួងនោះដែរឬអី?" បាទខ្ញុំបាទចង់ស្គាល់ដែរតែមិនដឹងជាហ្លួងនោះនៅឯណា អើបើឯងចង់ស្គាល់ហ្លួងនោះងាយទេ ចាំទៅដល់ទីជម្រំប្រជុំមនុស្សច្រើននោះកាលណា គេតែងតែដោះមួកគំនាប់ហ្លួង មនុស្សណាដែលមិនដោះមួកនោះមនុស្សនោះហើយជាហ្លួងពិតប្រាកដ ចូរឯងសំគាល់ថាជាហ្លួងចុះ" ៗ ឯក្មេងនោះបានឮដូច្នោះហើយ ក៏កំណត់កត់ចាំទុកក្នុងចិត្តលុះទៅដល់ទីទួលនោះឯបណ្ដាលមុខមន្ត្រីទាំងឡាយបានឃើញស្ដេចយាងទៅដល់ក៏នាំគ្នាត្រេកអរសាទរដោះមួកលើកដៃគំនាប់តាមទម្លាប់ ៗ

ឯមហាក្សត្រាធិបតី ស្ដេចនាំកុមារនោះចុះបាកខ្នងមនោម័យដល់ហើយស្ដេចបែរទៅនិយាយថា "ម្ដេចឯងបានឃើញគេដោះមួកគំនាប់អ្នកណាៗ មិនដោះមួកគំនាប់គេនោះ? ក្មេងនោះតបថា "ហ្លួងនោះខ្ញុំស្គាល់ហើយ? "ចុះឯងថាអ្នកណាជាហ្លួងចូរថាទៅមើល" ៗ "បាទ ហ្លួងនោះបើមិនរូបបងឯង គឺរូបខ្ញុំបាទ បើមិនខ្ញុំបាទក៏បងឯង ព្រោះមិនដោះមួកដូចគ្នា" ៗ ឯមហា

ក្សត្រាធិបតីបានស្តាប់កុមារនោះថ្លែងប្រាប់ ចេញមិនចំអង្គ វាគេវៀវយកទាំងរូបវាផងដូច្នោះហើយ ក៏ទ្រង់គិតថា ឯងបាន ប្រាប់វាថា "បើឃើញរូបណាមិនដោះមួកក្នុងកាលដែលប្រជុំ ជន រូបនោះឯងគឺហ្លួងហើយ ឥឡូវវាក៏មិនដោះ ឯងក៏មិនដោះ ដូចគ្នា បានជាវាចង្អុលរូបទាំង២ ថាបើមិនឯងក៏ខ្លួនវា បើមិនវា ក៏ឯងពាក្យវានោះជាពាក្យអ្នកឆោតខ្លៅ សំដៅព្រោះតែ ប្រាប់ទេឬ វាដឹងថាអញនេះជាហ្លួងហើយ បើវាដឹងច្បាស់ថា អញនេះជាហ្លួងហើយតែវាចង់ថារូបវាផងព្រោះឯងប្រាប់មុន នោះជាអាថ៌កំបាំងបន្តិច គឺថាអ្នកដែលមិនដោះមួក វាក៏មិន ដោះមួកដូចគ្នាវាអាអាទ៍ដើមនេះ ទើបវាថាវាផងហេតុដូច្នោះ ពាក្យវានោះបើពិគ្រោះទៅ គួរទៅជាពាក្យអ្នកមានបញ្ញា គឺជាពាក្យអ្នកប្រាជ្ញវិញបាន ពាក្យក្មេងយ៉ាងនេះ ប្រែមិន ចេញជា ប្រាជ្ញឬជាខ្លៅក៏ថាមិនបាន"។

ព្រះមហាក្សត្រ ស្តេចទ្រង់គិតវិញទៀតឃើញថាពាក្យ ក្មេងថានោះ គួរគិតយល់សេចក្តីថារូបស្តេចនេះនឹងសំដៅយក ត្រង់មិនដោះមួក ជាប្រមាណនោះមិនបាន រាស្ត្រគេមិនដោះ មួកវិញក៏មាន ដែលហៅថាស្តេចៗនោះ គឺសំដៅយកចំណេះ



វិជ្ជាការដែលប្រកបដោយសង្គហវត្ថុ៤ ប្រការនឹងទ្រង់ទសពិធ រាជធម៌ទាំង១០ ប្រការជាដើមទើបហៅថា ជាស្តេចជាហ្លួងបាន បើទៅយកត្រង់មិនដោះមួកឬមិនលើកដៃគំនាប់គេ សន្មតថា ជាមហាក្សត្រនោះ ក្មេងដែលវាមិនដោះមួក មិនលើកដៃគំ នាប់គេនោះ ក៏សន្មតថា មហាក្សត្របានដូចគ្នា ទើបវាថាបើ មិនឯងក៏អញបើមិនអញក៏ឯងយ៉ាងនេះ។

១ទៀតដូចពាក្យហៅថា លោកសង្ឃនោះគឺសំដៅយកត្រង់ ទ្រទ្រង់គុណធម៌ ប្រកបដោយនូវសីលទាំង៤ មានបាតិមោក្ខសំ វរសីលជាដើមផង ប្រកបដោយគុណធម៌របស់សមណៈ មាន អប្បច្ឆតាទិគុណគឺប្រាថ្នាតិចមានចិត្តសន្តោស ជាដើមផងទើប ហៅថាជាលោកសង្ឃបានក្នុងព្រះពុទ្ធសាសនានេះឯង បើទៅ យកត្រង់កោរក្បាលត្រងោល ស្លៀកពាក់សម្លត់ពណ៌លឿងជា ប្រមាណ ថាលោកសង្ឃនោះពួកបាសកក្មេងចាស់ ប្រុសស្រីមាន គេកោរក្បាលត្រងោលដែរ ឯស្លៀកពាក់សម្លត់លឿងនោះក៏ មានដែរ ម្តេចពួកនោះក៏មិនសន្មតនាមហៅថា លោកសង្ឃទៅ ផង។ ពាក្យក្មេងគង្វាលក្របីវាថានោះ គួរយកជាគតិលោកបា ន ហៅថាពាក្យបណ្ឌិតអ្នកប្រាជ្ញក្នុងលោកិយនេះបាន គួរឯង

ពិចារណាស្តាប់មើលចុះ ៗ

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស។

ចប់ភាគ ២ តែប៉ុណ្ណេះ។

---